។ បេ ។ យស្ស កម្មស្សិទំ ផលំ

๑– ជាណិតំ អហាមទាសី

๒– តិម្ពរុសកំ ។ បេ ។

๓– ឧច្ចទ្ធណ្ឌិកំ

๔– កកណ្ដកំ[๑]

๕– ឯឧបាលុកំ

๖– វល្លិបត្តំ[๒]

๗– ជារុសកំ

๘– ហត្ថប្បតាបកំ

๙– សាកមុដ្ឋី

๑๐– បុប្ផកមុដ្ឋី

๑๑– ម្ទុលកំ

๑๒– ឯឡុមុដ្ឋី

---

๑ ម. កក្កដកំ ។ ๒ ម. វល្លិផលំ ។

បណ្តាវិមានទាំងនោះ វិមាន ២៥ បណ្ឌិតគប្បីសំដែងឲ្យពិស្តារ ដូចវិភោគនទាយិកាវិមាន ផងចុះ ។

មានសម្បុរ ជ័រឆៅរឿង ។បេ។

សម្បុរបេះនាង កំភួចល្មាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្ត ត្រេកអរ ។បេ។ ផលនៃកម្មនេះថា

១	ខ្ញុំបានឲ្យ	ស្លាអំពៅ
២	។បេ។	ផ្ទៃទន្លាប់
៣		អំពៅ ១ កំណាត់
៤		ផ្ទៃត្រសក់
៥		ផ្ទៃល្ពៅ
៦		ផ្ទៃត្រសក់ស្រូវ
៧		ផ្ទៃមាក់ង្រាន
៨		ចង្ក្រានសម្រាប់កំដៅដៃ
៩		អន្ទក់ ១ ក្តាប់
១០		ផ្កា ១ ក្តាប់
១១		មើមដំឡូង
១២		ស្លឹកស្ពៅ ១ ក្តាប់

๑๓– អម្ពកញ្ជិកំ

๑๔– ឧច្ចាណិង្គុឡំ[๑]

๑๕– កាយពន្ធនំ

๑๖– អំសពន្ធកំ[๒]

๑๗– អយោកបត្តំ

๑๘– វិច្ឆបនំ

๑๙– តាលបណ្ណំ[๓]

๒๐– មោរហត្ថំ

๒๑– ឆត្តំ

๒๒– ឧបាហនំ

๒๓– បុប្ផំ

๒๔– មោឆកំ

๒๕– សក្ខលិ[๔] អហាមធាសិំ

ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស

តស្សា មេ បស្ស វិមានំ

អច្ឆរា កាមវណ្ណិនិមាមស្ថិ

អច្ឆរាសហស្សាហំ[๕] បវរា

---

๑ ម. ឧច្ចាណិង្គុឡំ ។ ๒ ឧ. អំសពន្ធកំ ។ ๓ ឧ. តាលវណ្ដំ ។ ๔ ម. សក្ខលិកំ ។ ๕ ឧ. អច្ឆរាសហស្សស្ស ។ ម. អច្ឆរាសហស្សស្សាហំ ។

១៣	ជ្រក់ស្វាយ
១៤	គ្រាប់ល្ងបុក
១៥	វត្តពន្ធចង្កេះ
១៦	យោគចាត្រ
១៧	សំពត់អយោគ
១៨	ផ្ទៃតមានជ្រុង ៤
១៩	ផ្ទៃតស្វឹកត្នោត
២០	ផ្ទៃតកន្ទុយក្អែក
២១	ឆត្រ
២២	សែ្បកជើង
២៣	នំ
២៤	ត្រវែ
២៥	ខ្ញុំបានប្រគេននំត្រវែ

ដល់គំនូរ ដែលគ្រាច់ទៅដើម្បីបិណ្ឌ ចាត

សូមលោកមើល នូវវិមានរបស់ខ្ញុំនោះចុះ

ខ្ញុំជាស្ត្រីអប្សរ មានសម្បុរ ដូចជាមាស

ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរពាន់មួយពាន់

បសន្ន បុញ្ញានំ វិបាកំ

តេន មេ តាទិសោ វណ្ណោ ។បេ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតំ ។

ស្វាគតំ វត មេ អជ្ជ សុប្បភាតំ សុហុដ្ឋិតំ
យំ អទ្ទសំ នេរវតាយោ អច្ឆក កាមវណ្ណិនិយោ
តាសាហំ[1] ឆម្មិ សុត្វាន ការហាមិ កុសលំ ពហុំ
ធារេន សមចរិយាយ សំយមេន ទមេន ច
សាហំ តត្ថ កមិស្សាមិ[2] យត្ថ គន្ត្វា ន សោចរេតិ ។

ទុត្តិលវិមានំ បញ្ចមំ ។

ឆដ្ឋំ ទុទ្ទសវិមានំ

(៣៤) ទទ្ទល្លមានា[3] វណ្ណេន យសសា ច យសស្សិនី
សព្ពេ នេរវេ តារតីសេ វណ្ណេន អតិរោចសិ[4]
ទស្សនំ ជាតិជាតានំ ឥទំ បឋមទស្សនំ
កេស្មា ការា ឧអាគម្ម ជាមេន ភាសសេ មមន្តិ ។

---

១ ម. ឥមាសាហំ ។ ២ម. ស្វាហំ តត្ថេវ គច្ឆាមិ ។ ៣ ម. ទទ្ទល្លមានោ ។ ម. ទទ្ទល្លមាន។
៤ ម. អតិរោចសិ ។

វិមានវត្ថុ ឆវិរិយត្តកវគ្គ ទី ៣ ។ ទុតិយវិមាន ទី ៦

សូមលោកមេលមើល នូវផលនៃបុណ្យទាំងឡាយ

ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំ ភ្លោកដូច្នោះ ។ បេ ។

ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ឧបរិ ដំណើរមកនៃអញក្នុងថ្ងៃនេះ ជាការល្អណាស់តើ ថ្ងៃនេះភ្លឺល្អ

ណាស់ ការក្រោកឡើង អំពីដំណេកល្អណាស់ ព្រោះអញបាន

ឃើញពួកទេវតា ជាស្ត្រីអប្សរមានសម្បុរជាទីគ្រាប់ថា អាត្មាអញ

នោះ បានស្តាប់ធម៌របស់ពួកទេវតាទាំងនោះ ទើបបានធ្វើកុសល

ច្រើន ដោយការឲ្យទានផង ដោយការប្រព្រឹត្តិសង្ឃមផង ដោយ

ការសង្រួមផង ដោយការទូន្មានផង អ្នកផង ទៅកន្លងទីណា

ហើយមិនសោយសោក អាត្មាអញនោះ ទើបទៅកន្លងទីនោះដែរ ។

ចប់ គុត្តិលវិមានទី ៥ ។

ទុតិយវិមាន ទី ៦

(៣៤) (នាងកញ្ញាសួរថា) នាងមានសម្បុរដ៏រុងរឿង មានយសកន្ជង

នូវពួកទេវតា ជាន់តាវត្តឹង្សទាំងអស់ ដោយយសផង ដោយសម្បុរផង

ខ្ញុំមិនដែលឃើញ(នាង)សោះ ឃើញម្ត៎ងនេះឈ្មោះថាឃើញជាដំបូង

នាងមកអំពីពួកទេវតាជាន់ណា បានជាមកហៅចំឈ្មោះរបស់ខ្ញុំ ។

អហំ ភន្តេ សុភទ្ទាសឹ បុព្ពេ មានុសកេ ភវេ
សមាភរិយោ ច តេ អាសឹ ភគិនី ច កនិដ្ឋិកា
សាហំ កាយស្ស ភេទាយ វិប្បមុត្តា តតោ ចុតា
ឯម្ហានរតិនេរយំ ឧបបន្នា សមាព្យតន្តិ ។
បហូតកតកល្យាណា តេ នេរយិ ឆ្តិ ចាលភិ នោ
យេសំ តុវំ កិត្តយិ សុភទ្ទេ ជាតិមត្តនោ
តេ ជី[1] តុវំ តេន វណ្ណេន តេន ច អនុសាសិតា
តីនិ សេនេវ ធានេន សុព្ពតេន យសស្សិនី
យសំ ឋានំ បត្តា វិសេសំ វិបុលមជ្ឈគា
នេវតេ បុច្ឆិតា ចក្ខុ កិស្ស កម្មស្ស ឥទំ ផលំ (ឥតិ) ។
អដ្ឋេវ បិណ្ឌចារានិ យំ ទានំ អទទំ បុរេ
ឧក្កំណោ យ្យស្ស សង្ឃស្ស ឧបដ្ឋាសេ តេ មហិចាលភិ
តេន មេ តាទិសោ វណ្ណោ ។ ឥមេ ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតិ ។

---

๑ ម. អបិ ។

(នាងសុភគ្គាឆ្លើយថា) ម្នាលនាងភគ្គា ខ្ញុំជាស្ត្រីឈ្មោះសុភគ្គា ខ្ញុំជាភរិយារួម(ប្តី) ជាមួយនឹងនាងផង ហើយត្រូវជាប្អូននាងផង ក្នុងភពជារបស់មនុស្ស ក្នុងកាលមុន ខ្ញុំនោះ លុះបែកធ្លាយកាយ ផុតស្រឡះ ច្យុតចាកមនុស្សលោកនោះ បានមកកើតជាមួយនឹងពួកទេវតា ជាន់និម្មានរតី ។

(នាងភគ្គាសួរថា) ម្នាលនាងសុភគ្គា នាងបានថ្លៃឆ្នូវជាតិរបស់ខ្លួន ក្នុងពួកទេវតាជាន់និម្មានរតីណា ពួកសត្វមានកម្មជាកុសលធ្វើហើយ ដ៏ច្រើន រមែងទៅកាន់ពួកទេវតាជាន់និម្មានរតីនោះ នាងអ្នកណាប្រៀនប្រដៅ ដោយហេតុដូចម្តេច ដោយប្រការដូចម្តេច នាងជាស្ត្រីមានយស ដល់នូវយសថែបនេះ បាននូវគុណ-វិសេស ដ៏ធំទូលាយ តើដោយទានដូចម្តេច ដោយវត្តល្អដូចម្តេច ម្នាលទេវតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(នាងសុភគ្គាឆ្លើយថា) ក្នុងកាលមុន ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទានណា ដោយដៃរបស់ខ្លួន ទាននោះគឺបិណ្ឌបាត[1] ៨ (ដៃលខ្ញុំឲ្យហើយ) ដល់សង្ឃ ជាទក្ខិណេយ្យបុគ្គល ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រកបដដូច្នេះ ។បេ។

សម្បុររបស់ខ្ញុំ ក៏ភ្លឺបង្ហាប់ សព្វទិស ។

---

១ បិណ្ឌបាតដែលបុគ្គលឲ្យដល់ភិក្ខុ ៨ រូប ។ អដ្ឋកថា ។

วิมานวตฺถุสฺมึ ตติยสฺส ปาริจฺฉตฺตกวคฺคสฺส ฉฏฺโ ทุติยวิมานํ

อหิ๋ตยา ๓หุตวเรกิกฺขุ สญฺญเต ๒ฺรหฺมจาริโน[๑]
ตปฺปสึ อฏฺฐาเสน ปสฏฺฐา สเกหิ ๓าณิหิ
ตยา ๓หุตวรํ ทตฺวา หีนกาย๎ปคา อหิ๋
กรีตฺวา อปฺปตวรํ ทตฺวา วิเสสิ๋ วิปุลมชฺฌคา
เสวเต ปุณฺณิกาจิกฺขุ กิสฺสกมฺมสฺมิ๋ ฉลิ(สกิ)ฯ
มเนกาวณฺณยา กิกฺขุ สณฺหิฏฺโ เม ปุเร อหุ
ตาหิ๋[๒]กเรน ฉิมเสสึ เวตึ อตฺตฆฏฺฏิ๋
เสา เม อตฺตปุเรกฺขาเร อฏฺฐกมฺปาย เวเต
สเฬฺว เสหีตึ มิ๋ อเวจ ตสฺสาหิ๋ วจนิ๋ กรึ
สา ทกฺขิณา สเฬฺวกตา อปฺปเมยฺยา ปติฏฺฐิตา
ปุณฺณเลสุ ตยา ทิฏฺโ ฉ ตึ ตว มหปฺผลนฺติ ฯ
๙๓าเสวหิ๋ ชานามิ สเฬฺว ทิฏฺโ มหปฺผลิ๋
สาหิ๋ ตฺวา มนุสฺสตฺตึ วเญฺ ปีตมจฺฉริ
สเฬฺว ทานิ ทสฺสามิหิ๋[๓] อปฺปมตฺตา ปุณปฺปุนนฺติ ฯ

---

๑ ม. ๒ฺรหฺมจริเย ฯ ๒ ม. ๓ลิ๋ ภเยฺ ทิมเสสึ ฯ ๓ ฉ. ๓าทิ ทสฺสามหิ๋ ฯ ม. ๓าทานิ ทสฺสามิ ฯ

(នាងកញ្ញាសួរថា) ខ្ញុំបានញ៉ាំងកិត្តិពាំងឲ្យាយ ដែលមានសេចក្តីសង្រ្គមប្រព្រឹត្តធម៌ដ៏ប្រសើរ ប្រើនលើសជាងនាង ឲ្យឆ្អែតស្កប់ស្កល់ដោយថ្ងាយទឹកឆ ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យទានដោយដៃរបស់ខ្លួន ប្រើនលើសជាងនាង ហើយចូលទៅគាន់កាយដោកបាប នាងឲ្យទានតិចជាងខ្ញុំទេ ប៉ុន្តែបានទៅតុណាវិសេសដ៏ធំទូលាយ តើដោយហេតុដូចម្តេចម្ចាលទៅតា ខ្ញុំសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(នាងសុកតាឆ្លើយថា) កិត្តិអ្នកញ៉ាំងចិត្តឲ្យចំរើន ខ្ញុំបានឃើញក្នុងកាលមុន ខ្ញុំបានទិមន្តព្រះវេតត្តេរនោះ មានខ្លួនជាគំរប់៨ដោយភត្ត ព្រះវេតត្តេរនោះ ធ្វើនូវប្រយោជន៍ធំ ដល់ខ្ញុំ ដោយសេចក្តីអនុគ្រោះ បានប្រាប់ខ្ញុំថា នាងចូរឲ្យ(ទាន) ចំពោះសង្ឃ ខ្ញុំក៏បានធ្វើតាមពាក្យលោក សង្ឃគតាទក្ខិណានោះ ជាទានមានផលប្រមាណមិនបាន ខ្ញុំបានដំកល់ទុកល្អហើយ ឯទានដែលនាងឲ្យហើយចំពោះបុគ្គលពាំងឲ្យាយ ទានរបស់នាងនោះ មិនមានផលប្រើនឡើយ ។

(នាងកញ្ញាឆ្លើយថា)ឥឡូវនេះ ខ្ញុំបានជឿជាស្រលះហើយថា ទានដែលបុគ្គលបានឲ្យចំពោះសង្ឃ ជាទានមានផលប្រើន ខ្ញុំនោះបើបានទៅកាន់អត្តភាពជាមនុស្ស ជឹងក្តីកាលណា ប្រាសចាកសេចក្តីកំណាញ់ មិនធ្វេសប្រហែស ទំនឹងឲ្យទានចំពោះសង្ឃរឿយ ។ ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

តោ ฝสา เทวตา อาเทฺ តយា មนฺตยเ เตสมา
สเพฺ เทเว ตาวตึสเ วณฺณน อติเรจติ (๙ติ) ฯ
มนุสฺสภูตา เทวินฺท ปุเพฺ มานุสเก ภเว
สมาภริยา จ เม อาสิ กกิณี จ กนิฏฺฐกา
สเพฺ ธาตาน นตฺตาน ตาตปุญฺญา วิเรจติ(๙ติ) ฯ
ฉเฑฺฑน ปุเพฺ กกิณี តយา อาเทฺ วิเรจสิ
យំ สงฺฆสฺมึ อปฺปเมยฺยา[๑] បតิฏฺฐาเปสิ ทกฺขิณำ
ปุจฺฉโต ปาโ มยา พุทฺธา ตินฺนกฺขเยสฺมึ ปพฺพเต
วิตาตกำ สีวิกาตสฺส យตฺถ ทินฺนำ มหปฺผลำ
យ ๘มาตาน มนุสฺสาน ปุญฺญเปกฺขาน ตาทีน
ตเรตำ ขิปติตกำ ปุญฺญำ យตฺถ ทินฺนำ มหปฺผลำ
តำ เม พุทฺธา วิยาตาสิ ตาน ตาทีน ตาทิน
วิตาตกำ[๒] สีวิกาตสฺส យตฺถ ทินฺนำ มหปฺผลำ
จตฺตาโร จ បដិបนฺนา จตฺตาโร จ ผเล ឋิตา
ฝส สงฺเฆ ขุชฺชุตโร បញฺญาสีลสมาหิโต

---

๑ ม. สงฺฆมฺหิ อปฺปเมยฺเย ฯ ๒ ม. วิภตำ ฯ

(ព្រះឥន្ទ្រសួរថា) ម្នាលនាងកញ្ញា ទេវតានេះ ត្រូវជាអ្វីនឹងនាង ក៏មកប្រឹក្សាជាមួយនាង តាំងសម្បុរភ្លឺរឿងកន្ទុងពួកទេវតា ជាន់តាវត្តឹង្ស ។

(នាងកញ្ញាឆ្លើយថា) បពិត្រព្រះអង្គជាធំជាងទេវតា កាលពីដើម ទេវតានោះកើតជាមនុស្ស ក្នុងកពង់នៃមនុស្ស បានជាភរិយារបស់ព្រះអង្គ ជាមួយនឹងខ្ញុំផង ហើយត្រូវជាប្អូនខ្ញុំព្រះអង្គផង បានឲ្យទាន តាំងពីក្មេយចំពោះសង្ឃ មានបុណ្យធ្វើហើយ ទើបចូរនរុងរឿងដូច្នេះ ។

(ព្រះឥន្ទ្រពោលថា) ម្នាលនាងកញ្ញា កាលពីដើម ប្អូនស្រីរុងរឿងដោយធម៌ជាងនាង ព្រោះបានញុំាងទក្ខិណាទាន ឲ្យដំកល់នៅស៊ប់ចំពោះសង្ឃ មានផលរាប់មិនបាន ដ្បិតព្រះពុទ្ធគង់លើកំពូលភ្នំ ខ្ញុំបានសួរនូវផលនៃការចែករំលែក ចំពោះបុគ្គលដែលគេឲ្យទានថា មានផលច្រើន ខ្ញុំបានសួរព្រះពុទ្ធអំពីបុណ្យ ដែលឲ្យផលក្នុងបច្ចុប្បន្ន របស់មនុស្សតាំងពីក្មេយ អ្នកឲ្យទាន ជាសត្វច្រើនដោយបុណ្យ ចំពោះពួកបុគ្គល ដែលគេឲ្យទានថា មានផលច្រើន កាលព្រះពុទ្ធជ្រាបប្បាសន្ទូវផលនៃកម្ម គឺវិបាកនៃការចែករំលែកចំពោះពួកបុគ្គលដែលគេឲ្យទានថា មានផលច្រើន ដោយព្រះអង្គឯង ហើយត្បាតបញ្ហានោះដល់ខ្ញុំ បុគ្គល ៤ ពួកអ្នកដល់នូវមគ្គ ទន្ទឹងបុគ្គល ៤ ពួកតាំងនៅក្នុងផលនេះឯង ហៅថាសង្ឃ លោកប្រតិបត្តិត្រង់ប្រកបដោយប្រាជ្ញានឹងសីល

យ ជមាជានំ មនុស្សជំ បុញ្ញបេក្ខាន ទាឝិនំ
តវភោតំ ឯបឝិកំ បុញ្ញំ សន្ទ្ឋ និដ្ឋំ មហាបលំ

ឍសោ ហំ សន្ទ្ឋោ វិបុលោ មហាក្ខតោ
ឍសបរិមេយ្យោ ឧទធីវ សាគវោ
ឍតេ ហំ សេដ្ឋា នរវីរិយសារតា[1]
បភង្ករា ឝម្មកថំ ឧទីរយន្តំ
តេសំ សុនិដ្ឋំ សុហុតំ សុយិដ្ឋំ
យេ សន្ទ្ឋមុនិស្ស ឝនន្តំ ឝានំ
សា ឝក្កិណា សន្ទ្ឋតា បតិដ្ឋិតា
អមាបលា លោកវិទូហំ វណ្ណិតា
ឍតាទិសំ បុញ្ញមនុស្សរន្តា
យេ វេឝជាតា វិឝរន្តិ លោកេ
វិនេយ្យ មច្ឆេរមលំ សមូលំ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

ទុល្លវិមានំ ឆដ្ឋំ ។

---

๑ ម. នរវីរសារវិកា ។

ព្រះពុទ្ធបានសំដែង នូវបុណ្យ ដែលឲ្យផល ក្នុងបច្ចុប្បន្ន
របស់មនុស្សទាំងឡាយ អ្នកឲ្យទាន ជាសត្វប្រាថ្នា នូវបុណ្យ
កាលធ្វើ ចំពោះសង្ឃ ដែលគេឲ្យទានហើយ មានផលច្រើន
ព្រោះថា សង្ឃទុំ ជាសង្ឃមានគុណដ៏ធំទូលាយ សង្ឃទុំ
ដូចជាសាគរដែលទ្រទ្រង់នូវទឹក មានដម្រៀកបង់មិនបាន ពួក
សាវ័កអ្នកមានសេចក្តីព្យាយាមដាំនវៈទាំងនេះ ជាអ្នកប្រសើរ
មែនពិត អ្នកធ្វើនូវពន្ធឹគឺញាណ(ដល់សត្វលោក)ហើយសំដែង
នូវធម្មកថា ពួកសត្វណា បានឲ្យវានទក្ខិណ ចំពោះសង្ឃ
(ទាននោះ) ឈ្មោះថា ពួកសត្វទាំងនោះ បានឲ្យល្អហើយ
បូជាតូចល្អហើយ បូជាធំល្អហើយ សង្ឃគតាទក្ខិណាទាននោះ
ឈ្មោះថា បុគ្គលដំកល់ទុកល្អហើយ ជាទានមានផលច្រើន
ព្រះសម្មាសម្ពុទ្ធទាំងឡាយ ជ្រាបច្បាស់នូវលោក ទ្រង់
សរសើរហើយថា ជនទាំងឡាយណា កាលវេញនូវបុណ្យ
វែលខ្លួនបានធ្វើ នូវទក្ខិណចំពោះសង្ឃប្រកបដូច្នោះ ហើយតែង
មានសេចក្តីត្រេកអរ រមែងត្រាច់ទៅកាន់លោក ជនទាំងឡាយ
នោះ ឈ្មោះថា កំចាត់បង់នូវមច្ចុរាជ គឺសេចក្តីកំណាញ់
ព្រមទាំងឫស មិនមានគេតិះដៀល រមែងទៅកាន់ឋានសួគ៌។

ចប់ ទុតិយវិមាន ទី ៦ ។

សត្តមំ សេសវតីវិមានំ

(๓๙) ឧលិកាវជតហេមជាលច្ឆន្នំ
វិចិត្តវិចិត្រទ្វជលមន្តសំ សុរម្មំ
ព្យម្ហំ សុនិម្មិតំ តោរណូបបន្នំ
ភជកូបកិណ្ណាមិទំ(๑) សុភំ វិមានំ
ភាតិ ចនេស និសា ឯកោ សុរិយោ
សរេន តមបនុទោ សហស្សរំសី
តថា តបតិ មិទំ តវ វិមានំ
ជលមិវ ធូមសិខោ និសេ ឯកគ្គេ
មុសតិវ ឧយំ សតេរិតាវ
អាកាសេ ឋបិតមិទំ មនុញ្ញំ
វីណាមុរជសង្ឃតាឧឃុដ្ឋំ
ឥទ្ធំ ឥជ្ជបុរំ យថា តវ មិទំ
បឧមកុមុទឧប្បលកុវលយំ
យោធិកា ភណ្ឌិកា ឆោជកា ច សន្តិ
សាលកុសុមិតបុប្ផិតា អសោកា
វិចិនឧមក្កសុកន្ធសេវិតមិទំ

---

๑ ម. រូបកូបកិណ្ណាមិទំ ។

សេសវត្ថុវិមាន ទី ៧

(៣៩) (ព្រះវង្គីសត្ថរពោលថា) អាត្មាបានឃើញវិមាននេះល្អ ដែលប្រកបដោយសំណាញ់ ជាវិការៈនៃកែវផលិកនឹងប្រាក់នឹងមាស មានដៃដ៏វិចិត្រដោយកែវផ្សេង ។ គួរឲ្យរីករាយដោយប្រពៃ ជាទីនៅដែលបុញ្ញកម្មនិម្មិតល្អហើយ ប្រកបដោយក្លោងទ្វារ ពេយ្យាយដោយខ្លាច់មាស ជាវិមានដ៏ល្អ ព្រះអាទិត្យឰដ៏អាកាស មានរស្មី ១ ពាន់ កំចាត់បង់នូវងងឹតក្នុងសរទកាល ញុំាងទិសទាំង ១០ ឲ្យភ្លឺ (យ៉ាងណាមិញ) វិមានរបស់នាងនេះ ក៏រុងរឿង យ៉ាងនោះដែរ វិមាននេះជាទីគាប់ចិត្ត តាំងនៅឰដ៏អាកាស ចាំងភ្នែក ដូចជាអណ្តាតភ្លើងរុងរឿងក្នុងវេលាយប់ ឬដូចផ្កែកបន្ទោរ ក្នុងទីបំផុតនៃពពកកំពុងឆេះដោយសំឡេងពិណ សំកោរ ស្គរ តាំង វិមានរបស់នាងនេះ ដូចជាប្ញរីរបស់ព្រះឥន្ទ្រ ដ៏ស្អាតស្តុកស្តម្ភ ទាំងឈូក.ស កុមុទ ទប្បុលក្រហម ទប្បុលខៀវ មានទាំងផ្កាយុថកា ផ្កាបុ្ណ្ណរ ផ្កានទោង ផ្កាសាលព្រឹក្ស ផ្កាអសោក សឹងតែកសុះកស្ទាយ វិមាននេះ ប្រសព្រំ ដោយក្លិនក្រអូប នៃឈើដ៏ទុតួមផ្សេង ។

វិមានវត្ថុស្មិំ តតិយស្ស ជាវិញ្ញត្តកវគ្គស្ស សត្តមំ សេសវត្ថុវិមានំ

សលឞ្ឈលពុជសុជកសំយុត្តា
កុសុកសុជុលិតលតា វលម្ពិនីហិ
មណិជាលសទិសយសស្សិនី
រម្មា ភោក្ខរណី ឧបដ្ឋិតា តេ
ឧទករុហា ច យេត្ថ បុប្ផជាតា
ថលជា យេវ សន្តិ រុក្ខជាតា
មានុសកា អមានុសកា ច ទិព្វា
សង្កេ(๑) តុម្ហំ ឯវេសនម្ហិ ជាតា
កិស្ស សមធមស្ស អយំ(๒) វិបាកោ
តោ ជានាសិ កម្មផលេនិធូបបន្នា
យថា ច តេ អធិកតមិទំ វិមានំ
តថនុបទំ អវចាសិ អច្ឆរាបខុមេតំ(๓) ។
យថា ច មេ អធិកតមិទំ វិមានំ
តោ ញុមយ្ហរច តោ រសជ្ឈចរិតំ
ទិព្យបិលវមាំ សកជនិណ្ណំ
ទិជការណ្ហាវ តោ កិលាភិជាទិតំ

---

๑ ម. សព្វេ ។ ๒ ម. សំយមទមស្សយំ ។ ๓ ម អវិចាសិ ច្ឆរាបម្ពេតំ ។

ម្នាលនាងមានយស ស្រះបោក្ខរណីប្រកបដោយឈើស្រល់ ខ្នុរសម្ងួនធំសុជកព្រឹក្ស[1] ប្រកបដោយឈើមានខ្លឹមខាងក្រៅ (មានគ្មោតធំដូចជាដើម) ទន្លីវល្លិ រីកស្គុះស្គាយ សំយុងចុះ ច្រោកដស្នើដោយបណ្តាញនៃកែវមណី ជាទីរីករាយ តាំងឡើង(ក្នុងទីជិតនៃវិមាន) របស់នាង បុប្ផជាតតាំងឡាយណា ដែលដុះក្នុងទឹកក្តី រុក្ខជាតិតាំងឡាយណា ដែលដុះលើគោកក្តី ជារបស់មនុស្សក្តី ជារបស់អមនុស្សក្តី ដ៏ជាទិព្វ (បុប្ផជាត ទន្លីរុក្ខជាតទាំងនោះ) បានដុះឡើង ជិតលំនៅរបស់នាង កន្លែងនេះ តើជាផលនៃការសូមទានដូចម្តេច នាងបានមកកើតក្នុងវិមាននេះ តើដោយផលនៃកម្មដូចម្តេច ម្យ៉ាងទៀត វិមាននេះ នាងបានដោយកម្មណា ម្នាលនាងមានពេមក្អែក-ឆ នាងគប្បីសំដែងកម្មនោះតាមលំដាប់បទ ។

(ទេវតាពោលថា) វិមាននេះហ្ន៎ក្រៃលែ ក្លៀក មាន់ទោរ ត្រាច់ទៅ មានហ្វូងបក្សីទឹក ទន្លីរាជហង្សត្រាច់ទៅ គឹកកង ដោយសត្វចង្កៀលខ្ទង គារើនធំសត្វស្ទាប(ឯទៀតៗជាច្រើន)

---

១ សុជកព្រឹក្សនេះ មានតែក្នុងទេវលោកធំតែប៉ុណ្ណោះ ក្នុងទីដទៃមិនមាន ។ អដ្ឋកថា ។

ជាជាសង្ខាឧកបុប្ផរុក្ខវិជា
ចាតលិជម្ពុអសោករុក្ខវន្តំ
យថា ច មេ អធិគតមិទំ វិមានំ
តន្តេ បវេទិសង្ឃមិ សុណោមហំ ភន្តេ
មតជវរបុរត្ថិមេ
ជាឧឡកតាមកោ ជាមអត្តំភន្តេ
តត្ត អហោសឹ បុរេ សុណិសា
សេសវតីតំ តត្ត ជាឆឹសុ មមំ
សាហំ អបច្ច តត្ត កម្មកុសលំ
នេវមនុស្សប្បជិតំ មហន្តំ
ឧបតិស្សំ ឯព្ភុតំ អម្ប្រមេយ្យំ
មុនិតមជា កុសុមេហិ អញ្ជេកិរឹ
បរមតតិតតញ្ច បូជយិត្វា
អន្តិមនេហជរំ ឥសឹ ឧឡារំ
បហាយ មានុសកំ សមុស្សយំ
តំនសាគតា ឥធមាវសាមិ ហំនន្តិ ។

សេសវតីវិមានំ(๑) សត្តមំ ។

---

๑ ម. សេវតីវិមានំ ។

មានដើមច្រនៀង ដើមត្រឹង ដើមអសោក មានឈើច្រកប
ដោយផ្កាជាបណ្តាញមានប្រការផ្សេង ។ ដែលខ្ញុំបានហើយ
ដោយកម្មណាផង វិមាននេះដែលខ្ញុំបានហើយ ដោយកម្ម
ណាផង ខ្ញុំទទឹងសំដែង កម្មនោះ ។ ដល់លោកម្ចាស់បពិត្រ
លោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ ចាំស្តាប់ចុះ បពិត្រ
លោកម្ចាស់ដ៏ចំរើន មានស្រុកមួយឈ្មោះនាឡកៈ នៅក្នុង
ដែនមគធៈដ៏ច្រើរ នាទិសខាងកើត កាលពីដើម ខ្ញុំព្រះ
ករុណាជាកូនប្រសា (ក្នុងគហបតិត្រកូល) ក្នុងស្រុកនាឡកៈ
នោះ ពួកជនក្នុងស្រុក ស្គាល់ខ្ញុំថា នាងសេសវតី ខ្ញុំនោះ
បានសន្សំ នូវកុសលកម្ម ក្នុងស្រុកនោះ ខ្ញុំមានចិត្តរីក
រាយ បានបូជាផ្កាដល់ព្រះទុបតិស្សត្ថេរ ដែលទេវតាធំដ៏
មនុស្សបូជាហើយ លោកមានគុណដ៏ធំ បរិនិព្វានហើយ
មានគុណប្រមាណមិនបាន លុះខ្ញុំបានបូជាលោកអ្នកស្វែង
រកនូវគុណដ៏លើសលុប ទ្រទ្រង់រាងកាយជាទីបំផុត បាន
ដល់តតិយាងគ៌ក្រៃលែង ហើយខ្ញុំលះបង់កាយជារបស់មនុស្ស
បានមកកាន់ទេវនិកាយជាន់តាវត្តឹង្ស នាឋានទេវលោកនេះ ។

ចប់ សេសវតីវិមានទី ៣ ។

អដ្ឋមំ មល្លិការវិមានំ

(๓๒) បីតវត្ថេ បីតឆទេ បីតាលង្ការភូសិតេ
បីតគន្ធាហិ វក្ខហិ អបិលង្ការសោភិតេ
កកកុត្តកាយុរធរេ[๑] កាញ្ចនាវេឡភូសិតេ
ហេមជាលកសញ្ឆន្នេ ជាតរតនមាលិនី

សោវណ្ណមយា លោហិតង្គមយា ច
មុត្តាមយា វេឡុរិយាមយា ច
មសារគល្ហា សហាលោហិតង្គា[๒]
ចារវេតក្ខីហិ មណីហិ ចិត្តតា
កោចិ កោចិ វិត្ត មយ្ហសុស្សវេ
ហំសសុវ រញ្ញោ ករវីកសុស្សវេ
តេសំ សវេ សុយ្យតិ វក្កវោ
បញ្ជលិកំ តុរិយមិវប្បវាទិតំ

វថោ ច តេ សុភោ វក្ខ ជាជាវតនចិត្តង្គោ
ជាជាវណ្ណាហិ[๓] ជាតូហិ សុវិភត្តោ វ សោភតិ

---

๑ ម. កកកុកាយុរធរេ ។ ๒ ម. សហលោហិតង្គា ។ ๓ ម. ជាជាវណ្ណាហិ ។

មល្លិការវិមានទី ៨

(៣៦)(នារទត្ថេរសួរថា)ម្នាលនាងមានសំពត់លឿង មានទង់លឿង ស្អិតស្អាង ដោយគ្រឿងអលង្ការលឿង នាងបើកុងជាមិនប្រដាប់ដោយសំពត់ស្បែកមានពណ៌លឿងគាំងឡាយ មានសាច់ដ៏ល្អិតក៏ដោយ ក៏នៅតែល្អ ម្នាលនាងអ្នកទ្រទ្រង់នូវគ្រឿងប្រដាប់ដែជាវិការៈនៃមាស ស្អិតស្អាងដោយក្រលែជាវិការៈនៃមាស ពាសពេញដោយបណ្តាញ ជាវិការៈនៃមាស នាងជាអ្វី នាងមានកម្រងកែវផ្សែង ។

កម្រងជាវិការៈនៃមាសផង ជាវិការៈនៃកែវមណីមានពណ៌ក្រហមផង ជាវិការៈនៃកែវមុក្តាផង ជាវិការៈនៃកែវពិទូរ្យផង កែវពព្រួសផង មួយអន្ទើរដោយកែវមានពណ៌ក្រហមផង ដ៏វិចិត្រដោយកែវគាំងឡាយ ប្រាកដស្មើដោយក្អែកព្រាប បណ្តាកម្រងគាំងទុះ កម្រងមួយ ។ មានសូរពីរោះដូចសម្រែងក្អែក ដូចសម្រែងកដហង្ស(ប្តូ)ពីរោះដូចសម្រែងកវៃក សូរកម្រងគាំងនោះ មានភាពពីរោះ ពួកហាក់ដូចជាតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលគេប្រគំហើយ គាំងវេ របស់នាង ក៏មានសភាព ស្អាតល្អ មានអាយៈដ៏វិចិត្រហើយ ដោយកែវផ្សែង ។ ដែលផាង ចាត់ចែងហើយដោយជាតុ[1] គាំងឡាយ មានពណ៌ផ្សែង ។ សមល្អ

---

១ ដោយសម្ភារៈមានទ្រូពងនិងបង្គោលជាដើម ។ អដ្ឋកថា ។

សុត្តន្តបិដកេ ខុទ្ទកនិកាយេ ឋេរគាថាវណ្ណនា

តស្មិំ វជេ ភាតរិ ជាតវេទសា
យត្ថ[1] បិតា ភាសសិមំ បធេសិំ
នេវាតេ បុត្តិតា ចក្ខុ តាសុ្ស ភគ្គសុ្ស ឱនលត្តំ ។
សោវណ្ណមាលិំ មណិសោវណ្ណចិត្តំ[2]
មុត្តាចិត្តំ ហេមជាលេន ឆន្នំ[3]
បរិនិព្វុតេ តោតមេ អប្បមេយ្យេ
បសន្នចិត្តា អហមាភិរោមយិំ
តាហំ ភគ្គិំ ភរិត្វាន ភុសលំ ពុទ្ធវណ្ណិតំ
អបេតសោកា សុខិតា សម្ពុទ្ធមាមមាមយាតិ ។

មល្លិការវិមានំ អដ្ឋមំ ។

នវមំ វិសាលក្ខិវិមានំ

(៣៧) ភាយាមភ្ញិវិសាលក្ខី វម្មេ ចិត្តលតាវនេ
សមន្តា អនុបរិយាសិំ ជាវីតណាបុរក្ខិតា
យទា នេកិ តាវតឹសា បរិសន្តិ ឥមំ វនំ
សយោគ្គា សរថា សព្ពេ ចិត្រា ហោន្តិ ឥជាតតា
ភុយ្ហេញ្ច ឥធ បត្តាយ ឧយ្យានេ វិតរន្តិយា
ភាយេន ទិស្វាតិ ចិត្តំ ភោគេ ភូបំ តវេទិសំ

---

១ ម.ម. យា ត្វំ ។ ២ ម. មណិសោវណ្ណចិត្តិតំ ។ ៣ ម. សញ្ឆន្នំ ។

នាងបឋមនៅលើវេទនោះ មានពណ៌មានរូបប្រៀប
ដោយមាស ញុំាងប្រទេសនេះ ឲ្យភ្លឺរុងរឿង
ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។
(ទេវធីតាឆ្លើយថា) ខ្ញុំមានចិត្តជ្រះថ្លា បំពោះព្រះគោតម
ព្រះអង្គមានគុណប្រមាណមិនបាន ដែលទ្រង់ចំរើនញាន
ហើយ បានបូជាបណ្តាញមាសដ៏វិចិត្រ ដោយកែវមណី
ទឹងមាសរំលេចដោយកែវមុក្តា ចាំងដោយសំណាញ់មាស
ខ្ញុំបានធ្វើកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ ច្រាស
ចាកសេចក្តីសោក ដល់នូវសេចក្តីសុខ មានចិត្តត្រេកអរត្រាម ។

ចប់ មល្លិកាវិមានទី ៨ ។

វិសាលក្ខិវិមាន ទី ៩

(៣៧) (សក្កទេវរាជសួរថា) ម្នាលនាងមានភ្នែកខួលាយ នាង
ឈ្មោះអ្វី ឪពុកជា មានពួកនារីចោមរោម ហើយដើរក្រឡឹង ដុំវិញ
ព្រៃចិត្តលតា ជាទីរីករាយ ពួកទេវតាជាន់តាវត្តឹង្ស ចូលទៅកាន់
ព្រៃនេះ ក្នុងកាលណា (កាលនោះ) ពួកទេវតាទាំងអស់ ព្រម
ទាំងយាន ព្រមទាំងវេជ ដ៏វិចិត្រ ក៏មកក្នុងទីនុ៎ះ មានកាលមក
ដល់ក្នុងទីនេះ ហើយត្រាច់ទៅក្នុងនន្ទវ័ន ចិត្តរមែងប្រាកដដោយ
កាយ រូបរបស់នាង ក៏ប្រាកដដូច្នេះ តើដោយហេតុដូចម្តេច

វិមានវត្ថុស្មឹ តតិយស្ស ជាវិញ្ញត្តកវគ្គស្ស នវមំ វិសាលក្ខិវិមានំ

នេវតេ បុច្ឆិតាចិក្ខ កតិសញ្ញកម្មសង្ខិធលំ(ឥតិ)។

យេន កម្មេន នេវិទ្ធ រូបំ មយ្ហំ ឥតី ច មេ

ឥដ្ឋំ ច អានុភាវោ ច តំ សុណោហិ បុរិន្ទទ

អហំ ភគិនិយោ រម្ភ សុនន្ទា ជាម ខុទាសំកា

សង្ខាសីលេន សម្បន្នា សិរិភាគវតា សទា

អច្ឆាទនញ្ច ភត្តញ្ច សេនាសនំ បទីបិយំ

អទាសឹ ខុជុភូតេសុ វិប្បសន្នេន ចេតសា

ចាតុទ្ទសឹ បញ្ចទសឹ យោ ច បក្ខស្ស អដ្ឋមឹ

ទាដិហារិយបក្ខញ្ច អដ្ឋង្គសុសមាគតំ

ខុទោសថំ ខុបវសឹ សទា សីលេសុ សំវុតា

ចាណាតិចាតា វិរតា មុសាវាទា ច សញ្ញតា

ថេយ្យា ច អតិចារា ច មជ្ជចាជា ច អារកា

បញ្ចសិក្ខាបទេ រតា អរិយសច្ចាន កោវិទា

ខុចាសិតា ចក្ខុមតោ តោតមស្ស យសស្សិនោ

តាសញ្ច មេញ្ញាតិកុលំ អាសិ សទា មាលាតិហារតិ

តាហំ ភគវតោ ជ្ជមេ សព្ពមេតំតិភេបយឹ

ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាថ្វើយថា) បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ តតិរំពិនឹងអានុភាពរបស់ខ្ញុំ (កើតឡើង) ដោយកម្មណា បពិត្រព្រះអង្គទ្រង់ព្រះនាមបុរិន្ទទេវៈ សូមព្រះអង្គស្តាប់ នូវកម្មនោះចុះ ខ្ញុំជាឧបាសិកា ឈ្មោះសុនន្ទា នៅក្នុងក្រុងភដ្ទគីរជាទីត្រេកអរ ជាស្ត្រីបរិបូណ៌ ដោយសទ្ធានឹងសីល ត្រេកអរក្នុងការចែករំលែកនូវទាន មានចិត្តជ្រះថ្លា បានឲ្យសំពត់សម្រាប់ស្បៃកដណ្តប់ផង កត្តផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះពួកព្រះអរិយបុគ្គល អ្នកមានចិត្តត្រង់ សព្វៗកាល ខ្ញុំបានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ ទឹងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង បានសង្រួមក្នុងសីលទាំងឡាយផង រៀរចាកបាណាតិបាតផង សង្រួមចាកមុសាវាទផង ផ្ងួយចាកការលួចផង ចាកការប្រព្រឹត្តកន្ទួង (ចិត្តស្វាមី)ផង ចាកការផឹកទឹកស្រវឹងផង សព្វៗកាល ហើយត្រេកអរ ក្នុងសិក្ខាបទទាំង ៥ ឈ្មោះសក្នុងអរិយសច្ចទាំងឡាយ ជាឧបាសិកានៃព្រះគោតមព្រះអង្គមានបញ្ញាចក្ខុ មានយស ឯត្រកូលនៃញាតិរបស់ខ្ញុំនោះតែងយកកម្រងផ្កា មកឲ្យខ្ញុំ សព្វៗកាល ខ្ញុំបានបូជាកម្រងផ្កានោះទាំងអស់ ចំពោះព្រះស្តូប នៃព្រះមានព្រះភាគ

ឧបោសថេវាហំ តទ្ទា មាលាគន្ធវិលេបនំ
ឋបេត្វា អភិរោចេសឹ បសន្នា សគ្គមាហិ ចាណាមាហំ
តេន តម្ហេន នេវិន្ទ រូបំ មយ្ហំ តតិ ច មេ
ឥទ្ធិ ច អានុភាវោ ច យញ្ច មាលាភិរោចយឹ
យញ្ច សីលវតី អាសឹ ន តំ តាវ វិបច្ចតិ
អាសា ច បបនមេ នេវិន្ទ សគ្គគាមិនី សិយន្តិ ។

វិសាលក្ខិវិមានំ ឧត្តរំ ។

ទុសមំ បារិប្ផត្តកវិមានំ

(៣៨) កាវិច្ចគ្គតេ កោវិឡារេ រមណីយេ មនោរមេ
និព្ភមាលំ តទ្ទមានា តាយដ្ឋំ សម្ប្បមោទិសំ
តិសប្ប តេ ឧទ្ទមានាយ អច្ឆរាដ្ឋេហិ សព្ពសោ
និព្ភ សន្ថ ដិច្ចវន្តិ សវនីយា មនោរមា
តិសប្ប តេ ឧទ្ទមានាយ អច្ឆរាដ្ឋេហិ សព្ពសោ
និព្ភ តទ្ទ បភាយន្តិ សុចិតទ្ទ មនោរមា
វិវត្តមានា តោយេន យោ វេណីសុ បិលន្ធនា

ខ្ញុំមានចិត្តជ្រះថ្លា ចាន់ទៅក្នុងថ្ងៃខ្ទេចខ្ទាសបង ហើយបូជាកម្រងផ្កា គ្រឿងក្រអូបគ្រឿងលាប ចំពោះព្រះសង្ឃ ដោយដៃរបស់ខ្លួន បពិត្រព្រះអង្គជាធំជាងទេវតា រូបរបស់ខ្ញុំ គតិ ឫទ្ធិ ទឹងអានុភាព របស់ខ្ញុំ (កើតឡើង) ដោយកម្មនោះ ដែលខ្ញុំបានបូជាកម្រងផ្កាក្តី ដែលខ្ញុំជាស្ត្រីមានសីលក្តី ការបូជានូវកម្រងផ្កា ទឹងការកក្អកសីល របស់ខ្ញុំនោះ មិនទាន់ឲ្យផលនៅឡើយ បពិត្រព្រះអង្គជាធំជាងទេវតា តែសេចក្តីប្រាថ្នារបស់ខ្ញុំថា សូមឲ្យខ្ញុំបានជាសកទាគាមិនី ។

ចប់ វិសាលក្ខីវិមាន ទី ៨ ។

បារិច្ឆត្តកវិមាន ទី ១០

(៣៨) (ព្រះមោគ្គល្លានសួរថា) កាលនាងកាន់ផ្កាវិសេសផ្សេងទាំងឡាយ ឈ្មោះបារិច្ឆត្តកព្រឹក្ស គួរកែកាយ គួរត្រេកអរនៃចិត្ត ហើយក្រងជាកម្រងទឹព្វ ប្រឡែង រីកកាយ សព្វាយ កាលដែលនាងកំពុងកំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួរជាទីរីកកាយនៃចិត្ត រមែងលាន់ឮ អំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ កាលដែលនាង កំពុងកំនោះ ភ្លេងទិព្វទាំងឡាយ មានភ្លេងក្រអូបគួរជាទីរីកកាយនៃចិត្ត រមែងផ្សាយចេញ អំពីអវយវៈតូចធំទាំងឡាយ ដោយសព្វគ្រប់ នាងជាកកាយ គ្រឿងប្រដាប់ ទាំងឡាយណា ឮដ៏ផ្អែមសក់ របស់នាង

វិមានវត្ថុស្មឹ តតិយស្ស ជាវិប្ផត្តកវគ្គស្ស ទុតិយំ ។

តេសំ សុយ្យតិ ឯក្ខាសោ តុរិយេ បញ្ចង្គិកេ យថា
វជិរសកា ភតញ្ជតា ឯតេន សម្ពកម្ពតា
តេសំ សុយ្យតិ ឯក្ខាសោ តុរិយេ បញ្ចង្គិកេ យថា
យាបិ[1] តេសិវស្មឹ មាលា សុចិកម្ពា មនោរមា
ឯតិ តន្តោ ឯិសា សព្ពា វុក្កា មញ្ជុសកោ យថា
ឃាយសេ តំ សុចិកម្មំ រូបំ បស្សសិ អមានុសំ
ឆេវតេ បុច្ឆតាចិក្ខ កិស្សកម្មស្សិទំ ផលំ(ឥតិ)។
បភស្សរំ អច្ឆិមន្តំ[2] វណ្ណតន្ធេន សញ្ញុតំ
អសោកបុប្ផមាលាហិ ពុទ្ធស្ស ឧបនាមយឹ
តាហិ កម្មំ ករិត្វាន កុសលំ ពុទ្ធវណ្ណិតំ
អបេតសោកា សុខិតា សម្ពមោទាមនាមយាតំ ។

ជាវិប្ផត្តកវិមានំ ទសមំ ។

ទុតិយំ

ទុទ្ធរំ ទុច្ចបល្លង្កំ លតា ច កុត្តិលេន ច
ឧទ្ធស្ស សេសវតី មល្លី[3] វិសាលក្ខិ ចារិនត្តកោ
វក្កោ តេន បវុច្ចតីតិ ។

ជាវិប្ផត្តកវិគ្គោ តតិយោ ។

---

១ ម, តស្សា ។ ២ ឃ, ម. អក្ខិមន្តំ ។ ៣ ម. ទុទ្ធស្ស បេសមល្លិកា ។

សំឡេងគឹកកង នៃគ្រឿងប្រដាប់តាំងឡាយនោះ ឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវឲ្យលំបាកមកប៉ះកំភួរម្រើកដោយខ្យល់ សូរនៃគ្រឿងប្រដាប់ត្រចៀកតាំងនោះ ឮដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ កម្រងផ្កាណា ឮដ៏សព្វរបស់នាង មានក្លិនក្រអូបឈ្ងុយឈ្ងប់ ជាទីតែកាយនៃចិត្ត (កូនកម្រងផ្កានោះ) រមែងផ្សាយទៅសព្វទិស ហាក់ដូចដើមខ្នុរភ្នាក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូប ដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) ខ្ញុំបានបង្អោនទូរកម្រងផ្កាអសោក មានវស្ដីភ្លឺផ្លេក ប្រកបដោយពណ៌នឹងកូន ចំពោះព្រះពុទ្ធ ខ្ញុំបានធ្វើទូរកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ បានប្រាសចាកសេចក្ដីសោក បានដល់នូវសេចក្ដីសុខ មានចិត្តត្រេកអរព្រម ។

ចប់ ចារិច្ឆត្តកវិមាន ទី ១០ ។

ឧទ្ទាន

មិយាយអំពីទុព្ភរវិមាន ១ ទុប្បុវិមាន ១ បល្លង្កវិមាន ១ លតាវិមាន ១ គុត្តិលវិមាន ១ ទន្តុលវិមាន ១ សេសវតីវិមាន ១ មល្លិកាវិមាន ១ វិសាលក្ខីវិមាន ១ ចារិច្ឆត្តកវិមាន ១ ព្រោះហេតុនោះ ទើបហៅថាវគ្គ ។

ចប់ ចារិច្ឆត្តកវគ្គ ទី ៣ ។

បត្តវគ្គោ មញ្ជិដ្ឋកវត្ថុ

បឋមំ មញ្ជិដ្ឋកវិមានំ

(៣៩) មញ្ជិដ្ឋកោ[1] វិមានស្មិំ សោវណ្ណាកាសុកេ សន្តេ
បញ្ចង្គិកេន តូរិយេន រមសិ សុបញ្ញតេ
តម្ហា វិមានា ឱរុយ្ហ ជិន្តិតា រតនាមយា
ឯតាទិសិ សាលវតិ បុប្ផិតំ សព្ពកាលិកំ
យស្ស យស្សេវ សាលស្ស មូលេ តិដ្ឋសិ នេរវេ
សោ សោ មុញ្ចតិ បុប្ផានិ ឯតមត្ថំ នុមុត្តមោ
ឯតាទិសិ សាលវតិ អាឆុតំ ទិដ្ឋសារិតំ
ឯតំ តវោ ទិសា សព្ពា រុក្ខោ មញ្ជុសកោ[2] យថា
ឃាយសេ តំ សុទិតន្តិ រូបំ បស្សសិ អមានុសំ
នេរវេ បុច្ឆិតាចិក្ខ កិស្ស កម្មស្សិទំ ផលន្តិ។

អហំ មនុស្សេសុ មនុស្សភូតា
ជាសឹ អយ្យេ កុលេ[3] អហុំ
ពុទ្ធិ ឯសិន្តិ ទិស្វាន សាលបុប្ផេហិ ឯកិរឹ
វិដំសកញ្ច សុភតំ សាលបុប្ផមយិំ អហំ
ពុទ្ធស្ស ឧបនាមេសឹ បសន្នា សគេហា ជាលិហា

---

១ ម. មញ្ជេដ្ឋកោ ។ ២ ម. មញ្ជុស្សកោ ។ ៣ ម. អយ្យេកុលេ ។

មញ្ជិដ្ឋកវគ្គ ទី ៤

មញ្ជិដ្ឋកវិមាន ទី ១

(៣៩) (ព្រះមោគ្គល្លានសួរថា) នាងត្រេកអរ ដោយតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ដែលគេប្រគំពីរោះ ក្នុងវិមានកែវផលិក ពណិហង្សជាទ ក្រាលខ្បាច់មាស នាងចុះចាកវិមាននោះ ដែលប្អូញប្អាកមនុមិត្តហើយ ជាវិការៈនៃកែវ ហើយចូលទៅកាន់ព្រៃសាលព្រឹក្សមានផ្កាកែសព្វកាល ម្នាលទេវតា នាងបរិតនៅជិតគល់សាលព្រឹក្សណា។ ដើមសាលព្រឹក្សនោះ។ ជាឈើដ៏ខ្ពស់ត្រមៃដ៏ខន់ទោរដម្រុះផ្កាចុះមក ព្រៃសាលព្រឹក្សក៏រំដួយដោយខ្យល់ត្រជាខ្យល់បក់មកកំរើយ។ មានពួកសត្វបក្សីនៅអាស្រ័យ ក្នុងកំផ្សាយទៅ សព្វទិស ដូចដើមដុះខ្ចាក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូប ដែលមិនមែនជាមនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងកុំប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) ខ្ញុំកាលកើត ជាមនុស្ស

ក្នុងពួកមនុស្ស ជាទាសី ក្នុងផ្ទះចៅហ្វាយ

ខ្ញុំបានឃើញព្រះពុទ្ធ កំពុងគង់ បានកោយកាយផ្កាសាលព្រឹក្ស ខ្ញុំមានចិត្តជ្រះថ្លា បានបូជាគ្រឿងប្រដាប់ត្រចៀក ដែលក្ងែល្អហើយ ជាវិការៈនៃផ្កាសាលព្រឹក្ស ចំពោះព្រះសម្ពុទ្ធ ដោយដៃរបស់ខ្ញុំ

វិមានវត្ថុស្មឹ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស ទុតិយំ បភស្សរវិមានំ

តាហំ កម្មំ កវិត្វាន កុសលំ ពុទ្ធវណ្ណិតំ
អបេតសោកា សុខិតា សម្ម្បមោទាមនាមយាតំ ។

មញ្ជិដ្ឋកវិមានំ[1] បឋមំ ។

ទុតិយំ បភស្សរវិមានំ

(៤០) បភស្សរាវរវណ្ណនិភេ
សុវត្ថវត្ថនិវាសនេ
មហាទ្ធិកេ ចន្ទនវុច្ចិតង្គេ
កាត្វំ សុភេ នេវតេ វន្ទសេ មមំ
បល្លង្កោ ច តេ មហាគ្ឃោ
ជាជារតនចិត្តិតោ វុច្ចិរោ
យត្ត ត្វំ និសិន្នា វិរោចសិ
នេវាជាវិវ ឧន្នទេ វិរេ
កីត្វំ បុរេ សុចរិតមាចរិកន្តេ
កិស្ស កម្មស្ស វិបាកំ អនុភោសិ
នេវលោកស្មឹ នេវតេ បុច្ឆតាចិក្ខ
កិស្ស កម្មស្សិទំ ផលន្តិ ។
បិណ្ឌាយ តេ ចរន្តស្ស
មាលំ ជាលិតញ្ច អធិកន្តេ

---

១ ម. មញ្ជេដ្ឋកវិមានំ ។

ខ្ញុំបានធ្វើកុសលកម្មនោះ ដែលព្រះពុទ្ធទ្រង់សរសើរហើយ បានជ្រាសចាក
សេចក្តីសោក ដល់នូវសេចក្តីសុខ មិនមានរោគ មានចិត្តត្រេកអរត្រេម ។

ចប់ មញ្ជិដ្ឋកវិមាន ទី ១ ។

បភស្សរវិមាន ទី ២

(៤០)(ព្រះមោគ្គល្លានសួរថា) ម្នាលទេវតាល្អ មានពន្លឺ
មានពណ៌ប្រសើរក្តឹងផ្ទៃ ស្មៀតសំពត់នពណ៌ក្រហម
ស្រស់ មានរឹទ្ធិច្រើន មានខ្លួនរុងរឿងហាក់ដូចប្រាសាទ
ដោយខ្ទឹមចន្ទន៍ នាងជាអ្វី មកថ្វាយបង្គំអាត្មា មួយទៀត
បល្ល័ង្ករបស់នាងមានតម្លៃច្រើន សឹងវិចិត្រ ដោយកែវ
ផ្សេងៗ ដ៏រុងរឿង នាងអង្គុយលើបល្ល័ង្ក ដ៏រុងរឿង
ដូចទេវរាជ (បិតនៅ) ក្នុងនន្ទនវន ម្នាលនាងដ៏ចំរើន
ក្នុងកាលមុន នាងបានប្រព្រឹត្តសុចរិតដូចម្តេច នាង
សោយផលកម្មដូចម្តេច ក្នុងទេវលោក ម្នាលទេវតា
អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) បពិត្រព្រះថេរៈ ដ៏ចំរើន
ខ្ញុំព្រះករុណា បានប្រតែន នូវផ្លាម្ទិះ នឹងស្ពាអំពៅ
ដល់លោកម្ចាស់ កាលនិមន្តទៅ ដើម្បីបិណ្ឌបាត

តស្ស កម្មស្សិទំ វិបាកំ
អនុភោមិ នេវលោកស្មឹ
ហោតិ ច មេ អនុតាបោ
អបកតំ ទុក្កិតញ្ច មេ កតេ
សាហំ ធម្មំ ជានេស្សាសឹ
សុនេសិតំ ធម្មករេន
តំ តំ វជាមិ កច្ចន្តេ
យស្ស មេ អនុកម្បិយោ
កោចិ ធម្មេសុ តំ សមាទបេថ
សុនេសិតំ ធម្មករេន
យេសំ អត្ថំ សទ្ធា ពុន្ទេ
ធម្មេ ច សង្ឃតនេ ច
តេ មំ អតិវិកេចន្តិ
អាយុជា យសសា សិរិយា
បតាបេន វណ្ណេន ទុត្តរិតរា
អញ្ញេ មហិទ្ធិកតរា មយា នេកតិ ។

ឧបាសកវិមានំ ទុតិយំ ។

ខ្ញុំទើបទទួលនូវផលនេះ នៃកម្មនោះ ក្នុងទេវលោក
បពិត្រព្រះថេរៈដ៏ចំរើន តែសេចក្តីក្តៅក្រហាយមាន
ដល់ខ្ញុំ ចាំងទោសកំហុស ដែលដល់នូវសេចក្តីទុក្ខ
(ក៏កើតឡើង) ដល់ខ្ញុំ (ព្រោះ)ខ្ញុំនោះ មិនបានស្តាប់ធម៌
ដែលព្រះពុទ្ធ ជាធម្មរាជ ទ្រង់សំដែងល្អហើយ
បពិត្រព្រះថេរៈដ៏ចំរើន ព្រោះហេតុនោះ ចានជាខ្ញុំ
និយាយទីឆលោកម្ចាស់ថា បុគ្គលណានីមួយ ដែលខ្ញុំ
គួរអនុគ្រោះ លោកម្ចាស់ចានដឹកនាំបុគ្គលនោះ ក្នុង
ធម៌ចាំងឡាយ ដែលព្រះពុទ្ធ ជាធម្មរាជ ទ្រង់សំដែង
ល្អហើយ សេចក្តីជឿចំពោះពុទ្ធរតនៈ ធម្មរតនៈនិង
សង្ឃរតនៈ មានដល់ទេវតាចាំងឡាយណា ទេវតា
ចាំងឡាយដទៃនោះ ច្រើនលើសលុប ដែលមានវិជ្ជា
ច្រើនជាងខ្ញុំ រមែងរុងរឿង កន្ទងនូវខ្ញុំ ដោយអាយុ
ដោយយស ដោយសិរី ដោយតេជៈ ដោយវណ្ណៈ ។

តតិយំ នាគវិមានំ

(๘๑) អលង្កតា កនកកញ្ចនាចិតំ[๑]
សុវណ្ណាជាលចិត្តំ មហាទ្ធំ
អភិរុយ្ហ កដវរំ សុកមជ្ឈិតំ
ឥជាកមា វេហាសយំ អន្តលិក្ខេ
ជាកស្ស ទន្តេសុ ទុវេសុ និម្មិតា
អច្ឆោទកា បទុមិនិយោ សុផុល្លា
បទុមេសុ តុរិយគណា បវជ្ជរេ
ឥមា ច នច្ចុន្តិ មនោហរាយោ
នេរិន្ទិបត្តាសិ មហានុភាវេ
មនុស្សភូតា កិមកាសិ បុញ្ញំ
កេនាសិ ឯវញ្ជលិតានុភាវា
វណ្ណោ ច តេ សព្ពទិសា បភាសតីតិ ។
ពារាណសិយំ ឧបសង្កមិត្វា
ពុទ្ធស្សាហំ វត្តយុតំ អនាសឹ
ថានាធិ វន្ទិត្វា ឆមា និសីទឹ
ចិត្តាវតំ[๒] អញ្ជលិកំ អការសឹ[๓]

---

๑ ម. មណិកនកញ្ចនាចិតំ ។ ម. មណិកញ្ចនាចិតំ ។ ๒ ម. វិត្តាវតំ ។ ម. វិត្តាហំ។ ๓ ម. អការសិ ។

នាគវិមាន ទី ៣

(៤១) (ព្រះវង្គីសត្ថេរដ៏មានអាយុសួរថា) នាងប្រជាជន់ខ្ពស់ហើយ ឡើងជិះដំរីប្រសើរ វិចិត្រដោយកែវមណីនឹងមាស បិទបាំងដោយបណ្តាញមាស ជាដំរីមានឫទ្ធិ ដែលបុញ្ញកម្មសម្រេចល្អហើយ (អង្គុយ) លើខ្នងដំរី ជាទីកែពាយមកឰដ៏អាកាស កន្លងទីនេះ ស្រះទាំងឡាយ មានទឹកថ្លា មានគុម្ពឈូក មានផ្ការីកស្គុះស្គាយ ដែលបុញ្ញកម្មនិម្មិតហើយ ត្រង់ភ្នំដំរីទាំងគូ ពួកតូរ្យតន្ត្រី ប្រគំលើផ្ការីកឈូកទាំងឡាយ មានពួកស្រីកែវមនោហរទាំងនេះកំពាំ (លើផ្ការីកឈូកទាំងនោះ) ម្នាលនាង មានអានុភាពច្រើន នាងដល់នូវឫទ្ធិនៃទេវតា នាងកាលកើត ជាមនុស្សតើបានធ្វើបុណ្យអ្វី នាងមានអានុភាពរុងរឿងយ៉ាងនេះផង ទាំងសម្បុរបស់នាង ក៏អាចញុំាងទិសទាំងពួងឲ្យភ្លឺបានផង តើដោយបុណ្យដូចម្តេច ។

(ទេវតាធ្វើយថា) ខ្ញុំបានចូលទៅកន្លងក្រុងពារាណសី បានថ្វាយសំពត់មួយគូដល់ព្រះពុទ្ធ ហើយថ្វាយបង្គំព្រះបាទ អង្គុយលើផែនដី មានចិត្តត្រេកអរ បានធ្វើនូវអញ្ជលិកម្ម ចំពោះព្រះអង្គ

ពុទ្ធោ ច មេ កញ្ចនសន្និកត្តជោ
អនេសយិ សមុទយក្ខន្ធិច្ចតំ
អសង្ខតំ ខុក្ខនិរោធសច្ចំ[1]
មគ្គំ អនេសយិ យតោ វិជានិស្សំ[2]
អប្បាយុកី កាលកតា តតោ ចុតា
ឧបបជ្ជា តិទសានំ[3] យសស្សិនី
សក្កស្សាហំ អញ្ញតរា បជាបតិ
យសុត្តរា ជាម និសាសុ វិស្សុតាតិ ។

នាគវិមានំ តតិយំ ។

បត្តុំ អលោមវិមានំ

(៤២) អភិក្កន្តេន វណ្ណេន យា ភុំ តិដ្ឋសិ នេវតេ
ឱភាសេន្តី ទិសា សព្វា ឱសធី វិយ តារកា
កោនេ តេ តាទិសោ វណ្ណោ ។បេ។

វណ្ណោ ច តេ សព្វទិសា បភាសតីតិ ។
សា នេវតា អត្តមនា មោក្ខល្យានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ

---

១ ម. ខុក្ខនិរោធសច្ឆិកតំ ។ ២ ម. វិជានិយំ ។ ៣ ម. ឧប្បន្នា តិទសគណា ។

ចំណែកព្រះពុទ្ធ ព្រះអង្គមានព្រះបម្មាដ៏ភ្លឺ ច្រោកជាស្មើ ដោយមាស ព្រះអង្គបានសំដែងសម្តែងយសច្ចធីដ៏ខ្ពស់ក្នុងសច្ច ជារបស់មិនទៀងផង បានសំដែងខ្ពស់ក្នុងនិរោធសច្ច ជាអសង្ខតធម៌ផង មគ្គសច្ចផង ដល់ខ្ញុំ ជាហេតុឲ្យខ្ញុំបានត្រាស់ដឹង ខ្ញុំជាស្ត្រីមានអាយុតិច ធ្លើមណោកាល ច្យុតមកកើត ក្នុងពួកទេវតា ជាន់តាវត្តឹង្ស ជាស្ត្រីមានយស ជាបជាបតីគ្រប់គ្នាមួយ របស់សក្កទេវរាជ ឈ្មោះនាង យសុត្តរា លើសទេវតាដទៃ ដោយទិសតាំងពាន់ ។

ចប់ នាគវិមាន ទី ៣ ។

អលោមវិមាន ទី ៤

(៤៦) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរភ្លឺរឿងញុំាងទិសតាំងពួងឲ្យភ្លឺចាស់ ដូចផ្កាយព្រឹក សម្បុរបស់នាងច្រោកជាដូច្នោះ តើ (សម្រេច) ដោយបុណ្យដូចម្តេច ។ បេ ។ តាំងសម្បុរបស់នាង ក៏ភ្លឺចាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ផលនៃកម្មនេះថា

អហាវ្ហ ពារាណសិយំ ពុទ្ធុសភ្ជនិច្ចនាទ្ធុនោ

អដ្ឋាសឹ សុក្ខកុម្ភាសឹ បសន្នា សគេហា ទាណិហា

សុក្ខាយ អលោណិកាយ ច បសន្ន[1]ផលំ កុម្ភាសមិណ្ឌិយា

អលោមំ សុទ្ធិតំ ធិស្វា កោ បុញ្ញំ ន ករិស្សតិ[2]

តេន មេ តាទិសោ វណ្ណោ ។បេ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតិ ។

អលោមវិមានំ ចតុត្ថំ ។

បញ្ចមំ កញ្ចិកទាយិកាវិមានំ

(๔๓)អតិក្កន្តេ វណ្ណេ យា តុំ តិដ្ឋសិ ទេវតេ

។បេ។ ឱសធី វិយ តារកា

តេន តេ តាទិសោ វណ្ណោ ។បេ។

វណ្ណោ ច តេ សព្ពទិសា បភាសតីតិ ។

សា ទេវតា អត្តមនា មោក្ខល្យានេន បុច្ឆិតា

។បេ។ យស្ស កម្មស្សិទំ ផលំ

អហំ អន្ធកវិន្ទស្មឹ ពុទ្ធុសភ្ជនិច្ចនាទ្ធុនោ

អទ្ទាសឹ តោលសមត្តា កំ កញ្ចិកំ តេលឆដ្ដិតំ

---

๑ ម. ផុស្ស ផលំ ។ ๒ ម. ករិស្សតីតិ ។

ខ្ញុំមានចិត្តជ្រះថ្លា បានប្រគេនទំកុម្ភាសក្រៀម ដល់ព្រះពុទ្ធជាអាទិច្ចពន្ធុ ទៀបក្រុងពារាណសី ដោយដៃរបស់ខ្លួន សូមលោកម្ចាស់មើលនូវផលនៃដុំទំកុម្ភាសក្រៀមផង ស្រាបផងចុះ អ្នកណាឃើញនាងអលោមា ជាស្រីដល់នូវសេចក្តីសុខហើយ ទើបមិនធ្វើនូវបុណ្យកើត ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំ ច្រាកដដូច្នោះ ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ អលោមវិមាន ទី ៤ ។

កញ្ចិកទាយិកាវិមាន ទី ៥

(៤៣) (ព្រះមោគ្គល្លានសួរថា) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។បេ។ ដូចផ្កាយព្រឹក សម្បុររបស់នាងច្រាកដដូច្នោះ តើសម្រេចដោយបុណ្យ ដូចម្តេច ។បេ។ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ដល់នៃកម្មនេះថា

ខ្ញុំបានប្រគេន នូវទឹកបបរ ដែលចំអិនល្មម ដោយផ្លែពុទ្រា អប់ដោយប្រេង ដល់ព្រះពុទ្ធជាអាទិច្ចពន្ធុ ក្នុងស្រុកឈ្មោះអន្ធកវិន្ទៈ

បិបួលាសសុណោន ច មិសឺ្សំ លាមជ្ឈគោន ច
អជាសឺ ខុជ្ឈកូតស្មឺ វិប្បសន្នេន ចេតសា
យា មហោសិតំ ការយេ្យ ចក្កាវត្តិស្ស រាជិនោ
ជាវ័ សព្វង្គកល្យាណី ភត្តុ ចាគោមនស្សិកា
ឯតស្ស[1] កញ្ចិកាជនស្ស កលំ ជាតេ្តន សោឡសឺ
សតំ និក្ខា សតំ អស្សា សតំ អស្សតរីរថា
សតំ កញ្ញាសហស្សានិ អាមុត្តមណិកុណ្ឌលា
ឯតស្ស កញ្ចិកាជនស្ស កលំ ជាតេ្តន សោឡសឺ
សតំ ហេមវតា ជាតា ឆឯសាធន្តា ខុទ្ទហ្ថិកា
សុវណ្ណាកប្បា មាតង្គា ហេមកប្បនិវាសសា
ឯតស្ស កញ្ចិកាជនស្ស កលំ ជាតេ្តន សោឡសឺ
ចតុដ្ឋំបិ ច នីហារិំ ឥស្សរំ យោជ ការយេ
ឯតស្ស កញ្ចិកាជនស្ស កលំ ជាតេ្តន សោឡសិន្តិ។

កញ្ចិកាជនិកាវិមានំ បញ្ចមំ ។

---

១ ម. ឯកស្ស ។

ខ្ញុំមានចិត្តជ្រះថ្លា ចំពោះព្រះពុទ្ធអ្នកឈ្នះត្រង់ ហើយប្រគេនវត្ថុណាយ
ប្រឡាំដោយដីប្លី ខ្ទឹមមើម នឹងវត្ថុមានក្លិនប្រហើរ នារីណាមាន
អាយុវ:ល្អសព្វ មានរូបមិនថោកថយ គួរមើលរបស់កស្តា គប្បីធ្វើ
ជាអគ្គមហេសីនៃស្តេចចក្រពត្តិ នារីនោះមិនដល់ចំណិតទី ១ នៃ
ចំណែកដែលគេចែកជា ១៦ អស់ភាវ: ១៦ ជង នៃការឲ្យទឹកបបរ
នេះឡើយ មាសភ្ពោ ១០០ សេះ ១០០ រថទឹមដោយមេសេះអស្សតរ
១០០ កញ្ញា ១ សែន ដែលពាក់កុណ្ឌលតែវមណី ក៏មិនដល់
ចំណិតទី ១ នៃចំណែកដែលគេចែកជា ១៦ អស់ភាវ: ១៦ ជង នៃ
ការឲ្យទឹកបបរនេះឡើយ ពួកដំរីដែលកើតក្នុងប្រទេសឈ្មោះហិមវន្ត
ចំនួន ១០០ មានកូនដ៏ចចន្ទោលរថ ចំរើនដោយកំឡាំងនឹងសន្តុះ
នឹងការប្រឹងប្រែង មានឱឡដង្គន់ជាវិការៈនៃមាស មានគ្រឿងប្រដាប់
សម្រេចដោយមាស ក៏មិនដល់ចំណិតទី ១ នៃចំណែកដែល
គេចែកជា ១៦ អស់ភាវ: ១៦ ជង នៃការឲ្យទឹកបបរនេះឡើយ
បុគ្គលណា ក្នុងលោកនេះ គប្បីធ្វើនូវភាពនៃខ្លួនជាធំ ក្នុងទីបទាំង ៤
បុគ្គលនោះ ក៏នៅតែមិនទាន់ដល់ចំណិតទី ១ នៃចំណែកដែល
គេចែកជា ១៦ អស់ភាវ: ១៦ជង នៃការឲ្យទឹកបបរនេះឡើយ ។

ឆដ្ឋំ វិហារវិមានំ

(๒๒) អតិក្កន្តេន វណ្ណេន យា តុំ តត្ថសិ ទេវតេ

ฯ បេ ฯ ឱសធី រិវ តារកា

តស្សា តេ នច្ចមានាយ អន្តលិក្ខេហិ សព្វសោ

ទិព្វា សទ្ទា និច្ឆរន្តិ សរទីយា មនោរមា

តស្សា តេ នច្ចមានាយ អន្តលិក្ខេហិ សព្វសោ

ទិព្វា គន្ធា បវាយន្តិ សុចិគន្ធា មនោរមា

វិវត្តមានា កាយេន យា វេឡីសុ បិលន្ធនា

តេសំ សុយ្យតិ និក្ខោសោ តុរិយេ បញ្ចង្គិកេ យថា

វដំសកា ភតច្ឆតា ភាតេន សម្បកម្បិតា

តេសំ សុយ្យតិ និក្ខោសោ តុរិយេ បញ្ចង្គិកេ យថា

យាបិ តេ សិរសិ មាលា សុចិគន្ធា មនោរមា

ភិន្នា តន្ធា និសា សព្វា វុក្កា មញ្ជូសកោ យថា

ឃាយសេ តំ សុចិគន្ធំ វូរំ បស្សសិ អមានុសំ

ទេវតេ បុច្ឆិតា ចិក្ខ កិស្សកម្មស្សិទំ ផលន្តិ ฯ

សាវត្ថិយំ មយ្ហ សខី អនន្ធេ

សង្ឃស្ស កាសេសិ មហាវិហារំ

តត្ថ បសន្នា អហមានុមោទិំ

វិហារវិមាន ទី ៦

(๔๔) (ព្រះអនុរុទ្ធត្ថេរសួរថា) ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ។បេ។ ដូចផ្កាយព្រឹក កាលដែលនាងកំពុងកំនោះ សំឡេងទំពូចាំងឡាយ គួរស្តាប់ គួរវើកកាយនៃចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំដោយសព្វគ្រប់ កាលដែលនាងកំពុងកំនោះ ក្លិនទំពូចាំងឡាយ មានក្លិនក្រអូប ជាទីវើកកាយនៃចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំ ដោយសព្វគ្រប់ កាលនាងងាកកាយ គ្រឿងប្រដាប់ចាំងឡាយឮដ៏ផង្គសក់ ក៏ឮសូរគឹកកង ដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រវឿលបក់មកប៉ះ ក៏កំរើតដោយឿលឮសូរគឹកកងដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ផ្កាកម្រងណាឮដ៏សិរ្យៈរបស់នាង មានក្លិនក្រអូប ជាទីវើកកាយនៃចិត្ត (ក្លិននៃផ្កាកម្រងនោះ) រមែងផ្សាយទៅសព្វទិស ដូចដើមឧទ្ទាក នាងតែងធុំក្លិនក្រអូបនោះ តែងឃើញរូប ដែលមិនមែនជារបស់មនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) បពិត្រព្រះអនុរុទ្ធដ៏ចំរើន (នាងវិសាខា) ជាសំឡាញ់របស់ខ្ញុំ ឲ្យជាងឆ្លើមហាវិហារឿបក្រុងសាវត្ថី ។ ខ្ញុំសូមចំពោះព្រះសង្ឃ ខ្ញុំជ្រះថ្លា វើកកាយ ចំពោះវិហារនោះ

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស វិមានវត្ថុ

ឥស្សា អគារញ្ច បិយញ្ច មេតំ
តាយេវ មេ សុទ្ធមុមោឧជាយ
លទ្ធំ វិមានញ្ចតនស្សនេយ្យំ
សមង្គតោ សោឧ្ឍសយោជនានិ
វេហាសយំ តច្ចតិ ឥទ្ធិយា មម

កម្ពូជាតរូ ឯវេសា មេ វិកត្តា ភាកសោ មិតា
ឧទ្ធំលមានា អាកន្តិ សមន្តា សតយោជនំ
ចោក្ខរញ្ញោ ច មេ ឯត្ត បុថុលោមឯសេវិតា
អន្តោឧតា វិឈ្ឈសន្តា សោវណ្ណាលុកសន្ថតា (១)
ជាតរូបមុមសញ្ឆន្នា បុណ្ណរីកសមោតតា
សុរភី សមវ្ហាយន្តិ មន្ទញ្ចមាលុតេរិតា (២)
ជម្ពុយោ បនសា តាលា ជាឧម្ពរេកេ វនានិ ច
អន្តោ ឯវេសនេ ជាតា ជាតរុក្ខា អរេបិតា (៣)
ជាតាតុរិយសង្ឃុដ្ឋំ អច្ឆរាគណាយោសិតំ
យោបិមំ សុបិនេ បស្សេ សោបិ វិត្តោ សិយា ឧភោ
ឯតាទិសំ អញ្ចតនស្សនេយ្យំ វិមានំ សព្វសោ បភំ
មម កម្មេហិ ឯព្វត្តំ អលំ បុញ្ញានិ កាតវេ ។

---

๑ ម. សោណ្ណាលុកសន្ថតា ។ ๒ ម. មន្ទញ្ចាលុតេរិតា ។ ๓ ម.ម. អរេបិមា ។

ព្រោះឃើញទ្វារផ្ទះគឺវិមារ ជាទីស្រឡាញ់នេះ ទើប
វិមានដែលខ្ញុំបានហើយ ដោយអនុមោទនា ដ៏បរិសុទ្ធ
នោះឯង ជាវត្ថុអស្ចារ្យ គួរមិលមើល ក៏ខ្ពស់ទៅ
ឰដ៏អាកាស អស់ ១៦ យោជន៍ជុំវិញ ដោយបុញ្ញវិទ្ធិនៃខ្ញុំ
ផ្ទះកំពូល ជាលំនៅរបស់ខ្ញុំ ដូចគេចែកដោយចំណែកស្មើគ្នា វុង
រឿងភ្លឺទៅ អស់ ១០០ យោជន៍ជុំវិញ ឯស្រះបោក្ខរណីតាំងឡាយ
របស់ខ្ញុំ ក្នុងទីនេះ ដែលពួកត្រីទឹកនៅអាស្រ័យហើយ មានទឹកឆៅថ្លា
ត្រាលដោយខ្លាច់មាស ដេរដាសដោយឈូកផ្សែង ។ ឆ្អែតដោយ
ឈូក·សតាំងឡាយ មានក្លិនក្រអូប ជាទីគាប់ចិត្ត ដែលខ្យល់បក់
ផ្សាយទៅ ដើមត្រើង ខ្នុរគ្នោត ដូង ព្រៃទឹងឈើផ្សែង ។ តាំងឡាយ
ជុំវិតលំនៅខាងក្នុង មិនចាប់ជាំឡើយ (វិមាននោះ) សឹងរងំដោយ
តូរ្យតន្ត្រីផ្សែង ។ គឹកកងដោយពួកស្ត្រីអប្សរ ពោះជនណាឃើញខ្ញុំ
ក្នុងការយល់សប្តិ ជននោះឯង គង់ត្រេកអរ វិមានបែបនេះ ជាទី
អស្ចារ្យ គួរមិលមើល ភ្លឺព្រោងព្រាត ដោយសព្វគ្រប់ តើតឡើង
ដោយបុញ្ញកម្មតាំងឡាយរបស់ខ្ញុំ បុគ្គលគួរធ្វើនូវបុណ្យតាំងឡាយ ។

វិមានវត្ថុស្មិំ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស ឆដ្ឋំ វិហារវិមានំ

តាយេវ តេ សុទ្ធនុមោទនាយ
លទ្ធំ វិមានព្ភុតទស្សនេយ្យំ
យោ ចេវ សោ ជានមធាសិ ជារី
តស្ស តតី ព្រហ្មា កុហឹ ឧបប្ផន្នោ សាតំ ។
យោ សោ អហុ មយ្ហ សខី កនន្តេ
សន្ធស្ស តោរេសិ មហាវិហារំ
វិញ្ញាតធម្មោ សោ អធាសិ ជានំ
ឧបប្ផន្នោ ឆិម្មានរតីសុ ទេវេសុ[1]
បជាបតី តស្ស សុនិម្មិតស្ស
អច្ឆិន្ទិយោ កម្មវិបាកតស្ស[2]
យមេតំ បុច្ឆសិ កុហឹ ឧបប្ផន្នោ សាតំ ។
កនន្តេ វិយ តោសិ អនញ្ញថា អហំ
តេន ហញ្ញេបិ[3] សមាធបេក្ខ
សន្ធស្ស ជាជានិ ធម្មំ វិត្តា
ធម្មញ្ច សុលាភ បសន្នមានសោ
សុទ្ធស្ស តោ លទ្ធោ មនុស្សលាភោ
យំ មត្តំ មត្តាធិបតី អនេសយិ
ព្រហ្មសវោ តញ្ញនសន្ធិកត្តោ

---

๑ ម. ទេវេ ។ ๒ ម. តស្ស ។ ๓ ម. ហិ អញ្ញេបិ ។

(ព្រះអនុរុទ្ធត្ថេរសួរថា) វិមានដែលនាងបានហើយ ដោយអនុមោទនា ជំបរសុទ្ធនោះឯង ជាទីអស្ចារ្យ គួរមិលមើល ម្យ៉ាងទៀត នារីណា បានឲ្យទូវាន នាងចូរប្រាប់ទូវគតិ របស់នារីនោះ តើទៅកើតក្នុងទីណា ។ (ខេវគាធ្វើយថា) បពិត្រលោកដ៏ចំរើន ស្រីសំឡាញ់របស់ខ្ញុំណាបានឲ្យជាង៉ធ្វើមហាវិហារដើម្បីសង្ឃ ស្រីសំឡាញ់នោះ (គឺនាងវិសាខា) ជាស្ត្រីមានធម៌ ដឹងច្បាស់ បានឲ្យទានហើយ បានទៅកើតក្នុងទេវលោក ជាន់ទីម្ភានតី បានជាឋជាឋតីនៃទេវតាជឈ្មោះសុទិម្មិត លោកម្ចាស់សួរវេក ទូវនារីណាថា នារីនោះទៅកើតក្នុងទីណា ផលនៃកម្មរបស់នារីនោះ មិនគប្បីគិតឡើយ ។ បពិត្រលោកដ៏ចំរើន ខ្ញុំបានដោះស្រាយតាមសេចក្តីពិត មិនប្រែប្រួល ព្រោះហេតុនោះ លោកម្ចាស់ចូរបបួលពួកជនដទៃថា អ្នកទាំងឡាយ ចូរត្រេកអរឲ្យទានចំពោះសង្ឃផង អ្នកទាំងឡាយចូរមានចិត្តជ្រះថ្លា ស្តាប់ធម៌ផង ការបានអត្តភាពជាមនុស្ស ដែលគេកម្របានដោយលើសយ៉ាង អ្នកទាំងឡាយ ក៏បានហើយ ព្រះពុទ្ធ មានសំឡេងដូចព្រហ្ម មានព្រះចម្មាដូចមាស ជាអធិបតីក្នុងលោកផង បានសំដែងនូវទានជាផ្លូវណា

សង្ឃស្ស ទានានំ ផលានិ វិត្ថា
មហប្ផលា យត្ថ ករិត្វ ទក្ខិណា
យេ បុក្កលា អដ្ឋ សតំ បសដ្ឋា
ចត្តារិ ឋានានិ[1] យុតានិ ហោន្តិ
តេ ទក្ខិណេយ្យា សុគតស្ស សាវកា
ឯតេសុ និដ្ឋានិ មហប្ផលានិ

ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ
យដ្ឋមានានំ មនុស្សានំ បុញ្ញបេក្ខាន កាណិនំ
ករោតំ ឧបធិកំ បុញ្ញំ សង្ឃេ និន្នំ មហប្ផលំ
ឯសោ ហិ សង្ឃោ វិបុលោ មហគ្ឃតោ[2]
ឯសប្បមេយ្យោ ឧទធីវ សាគរោ
ឯតេហិ សេដ្ឋា នរវីរសាវកា[3]
បភង្ករា ធម្មមុទីរយន្តិ
តេសំ សុនិដ្ឋំ សុហុតំ សុយិដ្ឋំ
យេ សង្ឃមុទ្ទិស្ស ទទន្តិ ទានំ

---

๑ ម. យេតានិ ។ ๒ ម.ម. មហគ្ឃតោ ។ ๓ ម.ម. នរវីរសាវកា ។

ទក្ខិណាទាន(ដែលបុគ្គលឲ្យហើយ)ចំពោះសង្ឃណា ជាទាន
មានផលច្រើន អ្នកចាំឆន់ឡាយ ចូរត្រេកអរឲ្យទានចាំឆន់ឡាយ
(នោះ)ចំពោះសង្ឃ (នោះ)ចុះ បុគ្គលចាំឆន់ឡាយណា ៨ ពួក
ដែលសប្បុរសចាំឆន់ឡាយ សរសើរហើយ ចេញចាប់ជាគូបាន
៤ គូ បុគ្គលចាំឆន់ឡាយនោះ ជាសាវ័កនៃព្រះសុគត លោក
គួរដល់ទក្ខិណាទាន ទានចាំឆន់ឡាយ ដែលបុគ្គលឲ្យហើយ
ចំពោះទក្ខិណេយ្យបុគ្គលចាំឆន់ឡាយនុ៎ះ ជាទានមានផលច្រើន
បុគ្គល ៤ ពួក តាំងនៅក្នុងមគ្គ បុគ្គល ៤ ពួកតាំងនៅក្នុងផល នេះ
ឈ្មោះថាព្រះសង្ឃ លោកប្រតិបត្តិត្រង់ ប្រកបដោយបញ្ញាធឹងសីល
បុណ្យឲ្យផល ក្នុងបច្ចុប្បន្ន ដែលពួកសត្វជាមនុស្សប្រាថ្នាទូរបុណ្យ
កាលបូជាកាលធ្វើ បានឲ្យហើយចំពោះសង្ឃ ជាទានមានផលច្រើន
ព្រោះថា ព្រះសង្ឃនុ៎ះ ជាព្រះសង្ឃមានគុណ ធំទូលាយ
ព្រះសង្ឃនុ៎ះ ដូចជាសាគរ ដែលគ្រប់គ្រងទូវទឹក មានជម្រៅ
ពាប់មិនបាន ពួកសាវ័កអ្នកមានសេចក្តីព្យាយាម ប្រសើរជាង
នរៈចាំឆន់នេះ ជាអ្នកប្រសើរមែនពិត ជាអ្នកធ្វើនូវពន្ធឹ គឺ
ញាណ សំដែងនូវធម៌ ពួកសត្វណា បានឲ្យទាន ទុំសិ
ចំពោះព្រះសង្ឃ (ទាននោះ) ឈ្មោះថា ពួកសត្វទាំងនោះ
បានឲ្យល្អហើយ បូជាត្រូច ល្អហើយ បូជាធំ ល្អហើយ

วิหารวัตฺถุ์ จตุตฺถสฺส มญฺเจกวคฺคสฺส สตฺตมํ จตุรีติวิหารํ

สา ธกฺกิณา สงฺฆตา ปติฏฺฐิตา
มหาปฬา โลกวิจฺฉหิ วณฺณิตา
ฬตาธิสํ ปุญฺญมนุสฺสรนฺตา[๑]
เย เวธชาตา วิจรนฺติ โลเก
วิเนยฺย มจฺเฉรมลํ สมูลํ
อนินฺทิตา สคฺคมุเปนฺติ ฐานนฺติ ฯ

วิหารวิหารวิหารว

សង្ឃគតាទក្ខិណាទាននោះ ដែលបុគ្គលដំកល់ទុកល្អហើយ ជាទានមានផលច្រើន ដែលព្រះពុទ្ធទ្រង់ជ្រាបច្បាស់ នូវលោក ទ្រង់ត្រាស់សរសើរហើយថា ជនទាំងឡាយណា កាលវត្តកវៀយនូវបុណ្យ ប្រាកដដូច្នោះ រមែងកើតសេចក្តីត្រេកអរ ត្រាច់រង្គាត់ទៅ ក្នុងលោក ជនទាំងនោះ កំចាត់ចង់ នូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងឫស ជាអ្នកមិនមានតេតិះដៀលបាន រមែងទៅកាន់ឋានសួគ៌ ។

ចប់ វិហារវិមាន ទី ៦ ។

ចប់ ភាណវារៈទី ២ ។

បត្តវិត្តិវិមាន ទី ៧

(៤៩) (ព្រះមោគ្គល្លានសួរថា) មានសម្បុរដុំរុងរឿង ។ បេ ។ ទាំងសម្បុរបេះនាង ក៏ភ្លឺច្បាស់ សព្វទិស ។

ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ដល់នៃកម្មនេះថា

ខ្ញុំបានប្រគេនន្ទវាផ្កាកដក្រឹកមួយចាប់ ដល់កិកូកាលនិមន្ត ទៅចិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកតៈ ជាក្រុងគួរត្រេកអរ នៃពួកជនអ្នកនៅក្នុងផែនឯសិកៈ

តេនមេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន ។ បេ ។

វណ្ណោ ច តេ សព្ពទិសា បភាសតីតិ ។

សា នេវតា អត្តមនា មោក្ខល្យានេន បុដ្ឋតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ឆឡុប្បលហត្ថកំ អហាមធាសឹ

ភិក្ខុនោ បិណ្ឌាយ ចរន្តស្ស

ឯសិតាគំ ខុណ្ណតស្មឹ ឧតវេ

វវេ បណ្ណាកតេ[1] វម្មេ

តេនមេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតិ ។

អភិក្កន្តេន វណ្ណេន ។ បេ ។

វណ្ណោ ច តេ សព្ពទិសា បភាសតីតិ ។

សា នេវតា អត្តមនា មោក្ខល្យានេន បុដ្ឋតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

ទិជាតម្ពុលកំ ហារីតបត្តំ

ខុទកម្ហិ សវេ ជាតំ អហាមធាសឹ

ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។
តាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។
(ព្រះមោគ្គល្លានសួរថា) មានសម្បុរដ៏រុងរឿង ។បេ។
តាំងសម្បុរបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។
ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ដល់នៃកម្មនេះថា

ខ្ញុំបានប្រគេន នូវផ្កាឧប្បលខៀវមួយជាប់ ដល់ភិក្ខុ កាលនិមន្តទៅបិណ្ឌបាត ក្នុងនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះ បណ្ណកត: ជាក្រុងគួរត្រេកអរ នៃពួកជនអ្នកនៅក្នុងដែនឯសិត:
ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។បេ។
តាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។
(ព្រះមោគ្គល្លានសួរថា) មានសម្បុរដ៏រុងរឿង ។បេ។
តាំងសម្បុរបស់នាង ដ៏ភ្លឺច្បាស់ សព្វទិស ។
ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។បេ។ ដល់នៃកម្មនេះថា

ខ្ញុំបានប្រគេន នូវផ្កាឈូកមួយជាប់ ដែលមានក្រឡ-ស មានស្លឹកខៀវ ដុះក្នុងស្រះ មានទឹក

វិមានវត្ថុស្មឹ ចតុត្ថស្ស មញ្ជិដ្ឋកវគ្គស្ស សត្តមំ ចតុរិត្ថីវិមានំ

កិកុ្ខនោ បិណ្ឌាយ ចរន្តស្ស

ឯសិកាយំ ខុណ្ណាតស្មឹ ឧតរេ

វារេ បណ្ណាកតេ រម្ម

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតំ ។

អកិត្តន្តេន វណ្ណេន ។ បេ ។

វណ្ណោ ច តេ សព្ពទិសា បភាសតីតំ ។

សា នេវតា អត្តមនា មោក្ខល្យានេន បុដ្ឋតា

។ បេ ។ យស្ស កម្មស្សិទំ ផលំ

អហំ សុមនា សុមនស្ស សុមនមកុលាយ

ឧទ្ធវណ្ណាយ អមាមនាសិ

កិកុ្ខនោ បិណ្ឌាយ ចរន្តស្ស

ឯសិកាយំ ខុណ្ណាតស្មឹ ឧតរេ

វារេ បណ្ណាកតេ រម្ម

តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតំ ។

ចតុរិត្ថីវិមានំ សត្តមំ ។

វិមានវត្ថុ មញ្ជិដ្ឋកវគ្គ ទី ៤ ចតុរិត្ថីវិមាន ទី ៣

ជល់កំភុំ គាលនិមន្តវៅបិណ្ឌបាត កុដិនគរ
ជំប្រសើរ មានផែនដីខ្ពស់ ឈ្មោះបណ្ណកត:
គួរត្រេកអរ នៃពួកជនអ្នកនៅកុដិផែនឯសឹក:
ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។
ពាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។
(ព្រះមោគ្គល្លានសួរថា) មានសម្បុរដុំរុងរឿង ។ បេ ។
ពាំងសម្បុរបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។
ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ
។ បេ ។ ផ្តាំនៃកម្មនេះថា
ខ្ញុំឈ្មោះសុមនា បានប្រគេនផ្កាម្ទិះក្រពុំ មានពណ៌ប្រាកដ
ស្មើ ដោយភ្នុកដំរី ជល់កំភុំអ្នកមានចិត្តល្អ គាលនិមន្ត
វៅបិណ្ឌបាត កុដិនគរដ៏ប្រសើរ មានផែនដីខ្ពស់ ឈ្មោះ
បណ្ណកត: គួរត្រេកអរ នៃពួកជនអ្នកនៅកុដិផែនឯសឹក:
ព្រោះហេតុនោះ បានជាសម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ ។ បេ ។
ពាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ ចតុរិត្ថីវិមាន ទី ៣ ។

អដ្ឋមំ អម្ពវិមានំ

(៤៦) ឥទ្ធេ អម្ពវនំ រម្មំ ចាសាឧត្តេ មហល្លកោ
ជាតាតុរិយសង្ឃុដ្ឋោ[1] អច្ឆរាកណាយោសិតោ
បធិចោ ចេត្ត ផលតិ ឥច្ចុំ សោវណ្ណាយោ មហា
ខុស្សដលេហិ រុក្ខេហិ សមន្តា បរិវារិតោ
កោនុ តេ អម្ពវនំ រម្មំ ចាសាឧត្តេ មហល្លកោ
កោនុ តេ តាឥសោ វណ្ណោ ។ បេ ។

វណ្ណោ ច តេ សព្ពឥសា បភាសតីតំ ។
សា ឧវាច អត្តមនា មោក្ខល្យានេន បុច្ឆិតា
។ បេ ។ យស្ស កម្មស្សិទំ ផលំ
អហំ មនុស្សេសុ មនុស្សភូតា
បុរិមាយ ជាតិយា មនុស្សលោកេ
វិហារំ សង្ឃស្ស ការេសឹ អម្ពេហំ បរិវារិតំ
បរិយោសិតេ វិហារេ ការេត្តេ ឥដ្ឋេ មនោ
អម្ពេ អច្ឆាឧយំ ភ្ញាង[2] កត្វា ខុស្សមយេ ផលេ
បធិបំ តត្ត ជាលេត្វា គោផយិត្វា កល្យាត្តមំ
ឥយ្យាឧសឹ តំ សង្ឃស្ស បសន្នា សកេហិ ចាណិហិ

---

១ ម. ឆាឆាតុរិយសំឃុដ្ឋោ ។ ២ ម. អម្ពេហំ ឆាទយិត្វាន ។

អម្ពវិមាន ទី ៨

(៤៦) (ព្រះមោគ្គល្លានសួរថា) ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយ មានច្រាសាខខ្ពស់ធំទូលាយ ក្នុងព្រៃស្វាយនុ៎ះ សឹងរំដេះដោយគ្រប់តន្ត្រីផ្សេងៗ គឹកកងដោយពួកស្រីអប្សរ ពាំងប្រទីបភ្លាលាដ៏ធំជាវិការៈនៃមាស មានពួកឈើ ដែលផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ក៏ភ្លឺរុងរឿងក្នុងច្រាសាខនោះដាន់ច្ចៈ ព្រៃស្វាយរបស់នាងជាទិព្វ គួរសប្បាយ មានច្រាសាខខ្ពស់ធំទូលាយ តើសម្រេចដោយបុណ្យដូចម្តេច សម្បុររបស់នាង ប្រាកដដូច្នោះ តើសម្រេច ដោយបុណ្យដូចម្តេច ។ បេ ។ ពាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់ សព្វទិស ។ ទេវតានោះ ដែលព្រះមោគ្គល្លានសួរហើយ មានចិត្តត្រេកអរ ។ បេ ។ ដល់នៃកម្មនេះថា

ខ្ញុំកាលជាតិមុន កើត ជាមនុស្ស
ក្នុងពួកមនុស្ស នាមនុស្សលោក

បានឲ្យជាន់ធ្លីវិហារ ទុក្ខិសចំពោះសង្ឃ មានដើមស្វាយព័ទ្ធជុំវិញ កាលធ្លីវិហារបូរស្រេចហើយ បានធ្លីបុណ្យធ្វើ ខ្ញុំបានដណ្តប់រុំដើមស្វាយពាំងឲ្យ ធ្លើផ្លែពាំងឲ្យជាវិការៈនៃសំពត់ អុជប្រទីបភ្លឺរុងរឿង ក្នុងព្រៃស្វាយនោះ បានញុំាងព្រះសង្ឃដ៏ខត្តមជាន់គណៈឲ្យធាន់ ក៏មានចិត្តជ្រះថ្លា បានវេរវិហារនោះចំពោះសង្ឃដោយដៃរបស់ខ្លួន

តេន មេ អម្ពវនំ រម្មំ ចាសោទេត្ត មហាល្លកោ
ជាតាតុរិយសង្ឃុដ្ឋោ អច្ឆរាគណាយោសិតោ
បទីបោ ទេត្ត ជលតិ ឯំ សោវណ្ណាយោ មហា
ទុស្សដ្ឋលេហិ វុត្ថហិ សមន្តា បរិភារិតោ
តេន មេ តាទិសោ វណ្ណោ ។ បេ ។

វណ្ណោ ច មេ សព្ពទិសា បភាសតីតិ ។

អម្ពវិមានំ អដ្ឋមំ ។

នវមំ បីតវិមានំ

(៤៧) បីតវត្ថេ បីតធជេ[1] បីតាលង្ការភូសិតេ
បីតច្ចន្ទនលិត្តង្គេ បីតុប្បលមជាវធី
បីតប្បាសាទសយនេ បីតាសនេ បីតភោជនេ[2]
បីតច្ឆត្តេ បីតវេឋេ បីតសេរ្ស បីតវជនេ[3]
កឹ កម្មំ អកតំ កុសលំ ឯវរូបេ ឧបេ មាទិសកេ ភវេ
ទេវតេ បុច្ឆតិ ភិក្ខុ កិស្ស កម្មស្ស ឯំ ជលំ (ឥតិ) ។
កោសាតកី[4] នាម លតត្តំ ភន្តេ តំ ត្តំ[5] អនភិជ្ឈិតា

---

๑ ម. បីតវត្ថេ បីតធជេ ។ ๒ ម. បីតភាជនេ ។ ๓ ម. បីតពីជនេ ។ ๔ ម. កោសាតិកិ ។
๕ ម. កត្តុកា ។

ដោយបុញ្ញកម្មនោះ ទើបខ្ញុំមានព្រៃស្វាយ គួរសប្បាយមានប្រាសាទ
ខ្ពស់ធំខ្ពស់ណាយ ក្នុងព្រៃស្វាយនោះ សឹងរាំងដោយតូរ្យតន្ត្រីផ្សេងៗ
គឹកកងដោយពួកស្រីអប្សរ ទាំងប្រទីបផ្កាលាងធំ ជាវិការៈនៃមាស
មានពួកឈើផ្លែចេញជាសំពត់ព័ទ្ធជុំវិញ ក្លិនរឿង ក្នុងប្រាសាទ
នោះជានិច្ច សម្បុរបស់ខ្ញុំ ប្រាកដដូច្នោះ សម្រេចដោយបុណ្យ
នោះ ។បេ។ ទាំងសម្បុរបស់ខ្ញុំ ក៏ភ្លឺច្បាស់ សព្វទិស ។

ចប់ អម្ពវិមាន ទី ៨ ។

បឋវិមាន ទី ៩

(៤៧) (ទេវកញ្ញាសួរថា) ម្នាលនាងដ៏ចំរើន មានសំពត់លឿង
មានខន់លឿង ស្អិតស្អាងដោយគ្រឿងប្រដាប់មានពណ៌លឿង មាន
អាយុវៈលាបដោយខ្លឹមចន្ទន៍លឿង ទ្រទ្រង់ផ្កាឧប្បលលឿង មាន
ប្រាសាទមានពន្លឺដេកលឿង មានពីអង្គុយលឿង មានកោជនលឿង
មានធ្លក់លឿង មានរថលឿង មានសែះលឿង មានផ្ទៃតលឿង
នាងបានធ្វើអំពើដូចម្តេច ក្នុងកាលជារបស់មនុស្ស ក្នុងកាលមុន
ម្នាលទេវតា យើងសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

(ទេវធីតាឆ្លើយថា) បពិត្រព្រះអង្គដ៏ចំរើន វល្លិ៍ឈ្មោះកាសាតកី
(វល្លិ៍នោនព្រៃ) ជាជាតិវល្លិ៍ល្អីង ដែលគេមិនត្រូវការ

តស្សា ចត្តារិ បុប្ផានិ ថូបំ អភិហរឹ អហំ
សត្តសីរឹ ខុទ្ទិស្សរ វិប្បសន្នេន ចេតសា
ជាស្សរ មត្តំ អវេក្ខិស្សរ តទជ្ជមនសា សតី[1]
តតោ មំ អវធិ តារី ថូបំ អប្បត្តមានសំ
តញ្ចហំ អភិសញ្ចេយ្យរ កិយ្យោ[2] ទូន ឥតោ សិយា
តេន កម្មេន ទេវិន្ទ មយា ទេវកុញ្ជរ
បហាយ មានុសំ ទេហំ តរ សហព្យតមាគតាតិ[3] ។
ឥទំ សុត្វា តិទសាធិបតិ មយា ទេវកុញ្ជរេ
តាវត្តិំសេ បតរាទេន្តោ មាតលិ រថទព្ររ
បស្ស មាតលិ អច្ឆេរំ ចិត្តំ កម្មផលំ ឥទំ
អប្បតរម្បិ កតំ ទេយ្យរ បុញ្ញំ ហោតិ មហប្ផលំ
ឧត្តិ ចិត្តេ បសន្នម្ហិ អប្បកា ជាម ទក្ខិណា
តថាកតេ ភ សម្ពុទ្ធេ អថ ភ តស្ស សារកេ
ឥមិ មាតលិ អម្ហេបិ កិយ្យោ កិយ្យោមហោ[4]ស្ស
តថាកតស្ស ជាតុយោ សុខោ បុញ្ញានមុច្ចយោ
តិដ្ឋន្តេ ឯព្ភតេ ភបិ សមេ ចិត្តេ សមំ ផលំ

---

១ ម. ទតគ្គមនសោ សតិ ។ ២ ឱ. កីយោ ។ ៣ ម. សហព្យមាគតា ។
៤ ឱ. ម. មហេមសេ ។

ខ្ញុំម្ចាស់មានចិត្តជ្រះថ្លា បាននាំយកផ្កានោងឯព្រៃនោះ ៤ ទង ទៅបូជា
ព្រះស្តូប ទុកសំពោះព្រះសរីរធាតុនៃព្រះសាស្តា ខ្ញុំម្ចាស់កំពុងមានចិត្ត
ប្រព្រឹត្តទៅ ក្នុងព្រះធាតុនៃព្រះមានព្រះភាគនោះ មិនបានក្រឡេក
មើលផ្លូវគោនោះ គ្រានោះមេគោមកដល់ខ្ញុំម្ចាស់ ដែលមានអធ្យាស្រ័យ
មិនទាន់ដល់ព្រះស្តូប (ស្ងាប់ទៅ) បើខ្ញុំម្ចាស់សន្សឹកុណ្យនោះសម្រេច
ម៉្លេះសមជាមានសម្បត្តិដ៏លើសលុបជាងនេះ បពិត្រព្រះអង្គជាធំជាង
ទេវតា នាមមយរៈ ជាទេវកុញ្ញរ ខ្ញុំម្ចាស់បានលះបង់កាយជា
មនុស្ស មកកើតជាមួយនឹងព្រះអង្គ ព្រោះកម្មនោះ ។

ព្រះឥន្ទ្រ នាមមយរៈ ជាទេវកុញ្ញរ ជាធំជាងទេវតាក្នុងជាន់ត្រៃត្រឹង្ស
បានស្តាប់ពាក្យនេះហើយ ក៏ញុំាងទេវធីតាឲ្យជ្រះថ្លា ក្នុងកពតាវត្តីង្ស
ហើយ ឋានៈពាក្យនេះ នឹងមាតលិទេវបុត្រថា ម្នាលមាតលិ
អ្នកចូរមើលសេចក្តីអស្ចារ្យ នេះជាផលនៃកម្មដ៏វិចិត្រ ទេយ្យវត្ថុសម្បើ
បន្ទិចបន្តួចដែលគេធ្វើហើយ ជាបុណ្យមានផលច្រើន កាលបើចិត្ត
ជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវ័កបេះព្រះតថាគតហើយ
ទក្ខិណាទានឈ្មោះថាមានផលតិចមិនមែនទេឬ ម្នាលមាតលិ អ្នកចូរ
មក យើងទាំងឡាយនឹងបូជាព្រះធាតុព្រះតថាគតឲ្យលើសលុបជាងនេះ
ទៅទៀត ការសន្សឹកុណ្យទាំងឡាយ រមែងទាំមកនូវសេចក្តីសុខ
កាលព្រះតថាគតបរិនិព្វានទៅក្តី បរិព្វានទៅក្តី បើគាំងចិត្តស្មើ ផលក៏ស្មើ

ចេតោបណិធិហេតូ ហិ សត្តា កប្បដ្ឋិ សុក្កតឹ
ពហុង្គំ វត អត្តាយ ឧបច្ឆជ្ជិ តថាគតា
យត្ត ការំ ករិត្វាន សក្កំ កប្បដ្ឋិ ឋាយកាតិ។

បឋមវិមានំ ទសមំ ។

ទសមំ ឧប្បុវិមានំ

(៤៨) ឱភាសយិត្វា បឋវឹ សទេវកំ
អតិរោចសិ ចន្ទិមសុរិយោ វិយ
សិរិយា ច វណ្ណេន យសេន តេជសា
ព្រហ្មេវ ទេវេ តិទសេ សហិន្ទកេ
បុច្ឆាមិ តំ ឧប្បលមាលធារិនេ
អាវេឡិនេ កញ្ចនសន្និភត្តចេ
អលង្កតេ ឧត្តមវត្ថធារិនេ
កា តំ សុភេ ទេវតេ វន្ទសេ មមំ[1]
ឋានំ សុចិណ្ណំ អថ សីលសញ្ញមោ[2]
កេនូបបន្នា សុគតឹ យសស្សិនឹ
ទេវតេ បុច្ឆតាចិក្ខ កិស្ស កម្មស្សិទំ ផលំ (ឥតិ)។

---

១ ម. មម ។ ២ ម. សីលសញ្ញមំ ។

ដ្បិតថាសត្វទាំងឡាយ មានការដំកល់ចិត្តខុសជាហេតុ ទើបទៅកាន់សុគតិបាន ពាយកទាំងឡាយ រមែងទៅកាន់ស្ថានសួគ៌បាន ព្រោះធ្វើការបូជា ចំពោះព្រះតថាគតទាំងឡាយណា ព្រះតថាគតទាំងនោះ បានកើតឡើងក្នុងលោក ដើម្បីប្រយោជន៍ដល់ជនច្រើន ។

ចប់ បីតវិមាន ទី ៩ ។

ឧប្បុវិមានទី ១០

(៤៨) (ព្រះមោគ្គល្លានសួរថា) នាងរុងរឿងកន្ទុងពួកទេវតា ដោយសិរីផង ដោយសម្បុរផង ដោយយសផង ដោយតេជៈផង ដូចជាព្រះចន្ទ្រ នឹងព្រះអាទិត្យ ញុំាងផែនដីព្រមទាំងទេវលោកឲ្យភ្លឺរុងរឿង ឬដូចជាព្រហ្មរុងរឿងកន្ទុងពួកទេវតាក្នុងជាន់ត្រៃត្រឹង្ស ព្រមទាំងព្រះឥន្ទ្រ ម្នាលទេវតាអ្នកទ្រង់កម្រងផ្កាទប្បុល មានកួងផ្កាសម្រាប់ប្រដាប់ក្បាល មានសម្បុរស្មែកភ្លឺដូចមាស តាក់តែងគ្រឿងអលង្ការ ទ្រទ្រង់សំពត់ដ៏ទុតួម អាត្មាសូមសួរនាង ម្នាលទេវតា ល្អស្រស់នាងជាអ្វី មកថ្វាយបង្គំអាត្មា នាងបានសន្សំពានល្អហើយ ឬក៏នាងបានសង្រួម ក្នុងសីល បានមកកើត ក្នុងសុគតិជាស្ត្រីមានយស តើដោយហេតុដូចម្តេច ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់ នេះជាផលនៃកម្មអ្វី ។

ឥធន្តេ ភន្តេ ឥធមេវ[1] តាមំ
បិណ្ឌាយ អម្ហាកំ ឃរំ ឧបាគមិ
តតោ តេ ឧច្ចុស្ស អធាសឹ ទណ្ឌំ
បសន្នចិត្តា អតុលាយ បីតិយា
សស្សុ ច បច្ចា អនុយុញ្ជតេ មមំ
កហំ នុ ឧច្ចុំ[2] វជុ តេ អភាគរិ
ឯ ឆឌ្ឌិតំ ឧ បន ខាទិតំ មយា
សន្តស្សកំក្ខុស្ស សយំ អធាសិ
តុយ្ហញ្ចិទំ ឥស្សរិយំ អថោ មម
ឥតិស្ស សស្សុ បរិភាសតេ មមំ
លេឌ្ឌុំ តហេត្វា បហារំ អធាសិ មេ
តតោ ចុតា កាលកតម្ហិ ទេវតា
តទេវ កម្មំ កុសលំ កតំ មយា
សុខញ្ច កម្មំ អនុភោមិ អត្តនា
ទេវេហិ សទ្ធិំ បរិចារយាមហំ
មោទាមហំ កាមគុណេហិ បញ្ចហិ
តទេវ កម្មំ កុសលំ កតំ មយា
សុខញ្ច កម្មំ អនុភោមិ អត្តនា

---

១ ម. ឥធ តេ ភន្តេ ឥមមេវ ។ ២ ខ. ឧច្ចុ ។

